សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា** (SECC)


| | | | |
|---|---|---|---|
| តាក់តែងដោយ | | សាស្ត្រាចារ្យណែនាំ | |
| និស្សិតឈ្មោះ | **ហាក់ ស្រីល័ក្ខ** | លោក **ឈាង ហ៊ុយ** | |
| | **អ៊ឹង ហ៊ុយមាន** | | |
| ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ | | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាន់ទី ១០ | | ឆ្នាំសរសេររបាយការណ៍ | ២០១៧ |

# អារម្ភកថា

វិស័យមូលបត្រ គឺជាវិស័យមួយដែល កំពុងតែរីកដុះដាលជាលំដាប់នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីវិស័យហរិញ្ញវត្ថុ និងធនាគារបាននឹងកំពុងអភិវឌ្ឍរួចរាល់ទៅហើយ។ វិស័យមូលបត្រនេះផងដែរ ក៏ជាផ្នែកមួយនៃការជំរុញអោយអោយមានការរីកចំរើនដល់សេដ្ឋកិច្ចជាតិយើង តែថាប្រជាជន ឬមហាជនមួយចំនួននៅមិនទាន់យល់ដឹង និងស្គាល់ច្បាស់នូវវិស័យនេះនៅឡើយទេ។

អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំក្នុងនាមជានិស្សិតត្រៀមបញ្ចប់ការសិក្សា ហើយមានឱកាសបានរៀបចំរបាយការណ៍កម្មសិក្សា ក៏បានលើកយកនូវប្រធានបទមួយមកសិក្សានោះគឺ ដំណើរការបោះផ្សាយមូលបត្រនៃកម្ពុជា ដើម្បីជាទុនមួយផ្នែកទៀតនៃចំណេះដឹងដ៏ទូលំទូលាយផ្នែកមូលបត្រនេះ ក៏ដូចជាពង្រីកផ្សព្វផ្សាយពត៌មានក្នុងវិស័យមូលបត្រដល់បណ្តាក្រុមហ៊ុន/សហគ្រាស ឬមហាជនទាំងអស់ អោយបានស្វែងយល់ស៊ីជម្រៅយ៉ាងពិតប្រាកដ ថាដំណើរការបោះផ្សាយមូលបត្រ មានលក្ខណៈយ៉ាងណា អនុត្តន៍ដូចម្តេចខ្លះ ក៏មានការចូលរួមពីផ្នែកណាមួយផងដែរ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថាឯកសាររបាយការណ៍កម្មសិក្សាមួយនេះ អាចនឹងមានអត្ថប្រយោជន៍សំរាប់និស្សិតជំនាន់ក្រោយ ក៏ដូចជាការជំរុញបំផុសនូវចំណេះដឹង និងផ្តល់ជាពត៌មានសំរាប់វិនិយោគិនគ្រប់រូបផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំក៏សុំខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនាប្រការណាមួយ និងរង់ចាំការរិះគន់កែលំអរឡើងវិញពីសំណាក់សាស្ត្រាចារ្យ និងសិក្សានុសិស្សគ្រប់រូបដើម្បីអោយរបាយការណ៍មួយនេះកាន់តែល្អប្រសើរឡើងថែមទៀត។

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំឈ្មោះ **ហាក់ ស្រីលក្ខ** និង **អ៊ឹង ហ៊ុយមាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី ១០ ក្រុម$B_4C_6$ និង $B_4A_2$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៧ សូមគោរព និងសំដែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក និងអ្នកម្តាយ** ដែលលោកមានគុណទាំងពីរបានផ្តល់កំណើត និងធ្វើពលិកម្មលះបង់គ្រប់យ៉ាង ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សា ទូន្មាន អប់រំ និងប្រៀនប្រដៅសព្វបែបសព្វយ៉ាង ជាពិសេសគឺផ្តល់កំលាំងកាយកំលាំងចិត្ត និងកំលាំងស្មារតីចំពោះកូន រហូតដល់យើងខ្ញុំបានបញ្ចប់ការសិក្សា នៅសាកលវិទ្យាល័យ ក្រេបយកនូវចំណេះដឹងដ៏មានតម្លៃទុកជាទ្រព្យប្រចាំកាយដ៏ល្អឥតខ្ចោះពុំអាចកាត់ថ្លៃបាន។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំយកចិត្តទុកដាក់ បង្រៀន និងផ្តល់ចំណេះដឹង ផ្តល់ដំបូន្មាន ក៏ដូចជាបណ្តុះបណ្តាលយើងខ្ញុំទាំងអស់គ្នា អោយក្លាយទៅជាធនធានមនុស្សដ៏មានតម្លៃ នៅក្នុងសង្គម និងក្នុងប្រទេសរបស់យើងផងដែរ។

**លោក សាស្ត្រាចារ្យ ឈាង ហ៊ុយ** ដែលជាសាស្រ្តាចារ្យណែនាំក្នុងការស្រាវជ្រាវ និងសរសេររបាយការណ៍ សំរាប់ប្រធានបទរបស់យើងខ្ញុំ ក៏ដូចជាណែនាំ ចង្អុលបង្ហាញ ប្រៀនប្រដៅ និងផ្តល់ជាគំនិតយោបល់ល្អៗ អំពីវិធីរៀបចំ ស្រាវជ្រាវរាល់ពត៌មានទាំងឡាយ ជាពិសេសគឺកែលំអរកំហុសឆ្គងដែលកើតមានឡើងដែលខានមិនបាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីចងក្រងរបាយការណ៍នេះអោយទទួលបានជោគជ័យ។

ឯកឧត្តមអគ្គនាយក និងឯកឧត្តមអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា បណ្តាបុគ្គលិកគ្រប់នាយកដ្ឋាន និងជាពិសេសនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ និងជាពិសេស**លោក រិន រដ្ឋា អ្នកស្រី ហ៊ី លីតា និង លោក ម៉ុក រ៉ាឌី ព្រមទាំងបណ្តាបងៗ**រួមការងារនៅក្នុងនាយកដ្ឋាន បានជួយជ្រុំជ្រែង ផ្តល់ជាចំណេះដឹងបង្ហាត់បង្រៀន ក៏ដូចជាពន្យល់ណែនាំ ចង្អុលបង្ហាញចំណុចផ្សេងៗដែលជាគោលបំណងរួមអោយយើងខ្ញុំទទួលបានចំណេះដឹងថ្មីៗទាក់ទងនឹងវិស័យមូលបត្រ ជាពិសេសគឺរបាយការណ៍កម្មសិក្សាមួយនេះផងដែរ។

**វៀមច្បងតាំងឡាយគ្រប់ជំនាន់** ដែលបានបន្សល់នូវស្នាដៃល្អៗសម្រាប់សិស្សប្អូនជំនាន់ក្រោយបានមើល និងយកធ្វើជាគំរូក្នុងការស្រាវជ្រាវ និងរៀបចំរបាយការណ៍របស់ខ្លួនឯង។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរចំពោះអ្នកមានគុណទាំងអស់អោយជួបប្រទះតែសុភមង្គល និងប្រសិទ្ធិពរជ័យពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

តារាងសំគាល់អក្សរកាត់....iv

បញ្ជីតារាង ....v

បញ្ជីរូបភាព ....vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា....១

២. ចំណោទបញ្ហា ....២

៣. គោលបំណងនៃការស្រាវជ្រាវ ....២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....២

៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ ....២

៦. សារៈសំខាន់នៃការស្រាវជ្រាវ ....៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....៣

## ជំពូកទី១

## រំលឹកទ្រឹស្តីវិស័យមូលបត្រនៅកម្ពុជា

១.១. និយមន័យមូលបត្រ ....៥

១.២ ប្រភេទនៃមូលបត្រ ....៥

១.២.១ មូលបត្ររដ្ឋ....៥

១.២.២ មូលបត្រមហាជន ....៥

១.៣ ទីផ្សារមូលបត្រ ....១០

១.៣.១ ទីផ្សារដំបូង....១០

១.៣.២ ទីផ្សារបន្ទាប់....១១

១.៤ តួអង្គសំខាន់ៗទាំង ៤ ក្នុងទីផ្សារមូលបត្រ (4Is)....១១

១.៥ អត្ថប្រយោជន៍ទីផ្សារមូលបត្រ ....១២

## ជំពូកទី២

## គណៈកម្មការមូលបត្រកម្ពុជាមូលបត្រកម្ពុជា

២.១ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ........ ១៦
២.១.១. ប្រវត្តិគណៈកម្មការទីផ្សារមូលបត្រកម្ពុជា ........ ១៦
២.១.២ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់ គ.ម.ក ........ ១៦
២.១.២.១. រូបសញ្ញា ........ ១៦
២.១.២.២. អត្ថន័យនៃរូបសញ្ញា ........ ១៧
២.២ ចក្ខុវិស័យ និង បេសកកម្ម ........ ១៨
២.២.១. ចក្ខុវិស័យ ........ ១៨
២.២.២. បេសកកម្ម ........ ១៩
២.៣ មុខងាររបស់ គ.ម.ក ........ ១៩
២.៤ សមាសភាពរបស់ គ.ម.ក ........ ២០
២.៥ រចនាសម្ព័ន្ធគ្រប់គ្រង គ.ម.ក ........ ២០

## ជំពូកទី៣

## ដំណើរការបោះផ្សាយមូលបត្រ (IPO) នៅកម្ពុជា

៣.១ តើអ្វីទៅជា IPO? ........ ២៧
៣.២ តួអង្គសំខាន់ៗដែលចូលរួមក្នុងកិច្ចដំណើរការ IPO ........ ២៨
៣.២.១ CSX ........ ២៨
៣.២.២ IPO team ........ ៣០
៣.២.៣ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ........ ៣៨
៣.២.៤ ក្រុមហ៊ុនបោះផ្សាយ ........ ៤២
៣.២.៥ វិនិយោគិនសាធារណៈ ........ ៤៣
៣.៣. យន្តការនៃការធ្វើ IPO ........ ៤៣
៣.៤. លក្ខខណ្ឌតម្រូវនៃការធ្វើ IPO? ........ ៤៦
៣.៤.១ ទីផ្សារគោល (Main Board) ........ ៤៦
៣.៤.២ ទីផ្សារកំណើន (Growth Board) ........ ៤៩
៣.៥. លក្ខខណ្ឌចូលរួមក្នុង ការចុះបញ្ជី ........ ៥១

៣.៦ ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូងសាធារណៈ.......................... ៥៣
៣.៦.១ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)........................................................................៥៣
៣.៦.២ ក្រុមហ៊ុនហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ហ.ធ.អ)..................៥៧
៣.៦.៣ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) ........................................................................................ ៥៩
៣.៦.៤ ក្រុមហ៊ុនភ្នំពេញ អេស អ៊ី ហ្សិត ភីអិលស៊ី (PPSP)........................................................ ៦២
៣.៦.៥ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)......................................................................... ៦៦
៣.៧ ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម........................................................................ ៦៩
៣.៧.១. ដំណាក់កាលប៊ុលបៀលឌីង ............................................................................................. ៦៩
៣.៧.២. ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ.......................................................៧១
៣.៨ រ៉ូដស្វ (RoadShow) ..........................................................................................................៧៣
៣.៩ ការគ្រប់គ្រងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងសាធារណៈ .................... ៧៤
៣.៩.១ ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ................................៧៥
៣.៩.២ ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ...............................................................៧៥
៣.៩.៣ កាផ្សព្វផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ........................................៧៦
៣.៩.៤ កម្រៃសេវាក្នុងការចុះបញ្ជី.................................................................................................៧៨

## សេចក្តីសន្និដ្ឋាននិងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន ............................................................................................................ ៨០
២. អនុសាសន៍ .................................................................................................................... ៨១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

| អក្សរកាត់ | អក្សរពេញ |
|---|---|
| គ.ម.ក | គណៈកម្មាការមូលបត្រកម្ពុជា |
| ផ.ម.ក | ផ្សារមូលបត្រកម្ពុជា |
| IPO | Initial Public Offering |
| រ.ទ.ស.ភ | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ហ.ធ.អ | ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី |
| ក.ស.ភ | កំពង់ផែស្វយ័តភ្នំពេញ |
| PPSP | Phnom Penh SEZ Plc ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី |

## បញ្ជីតារាង

តារាងទី១៖ បញ្ជីនាមក្រុមហ៊ុនដែលផ្តល់សេវាផ្នែកច្បាប់ក្នុងវិស័យមូលបត្រ ........................ ៣១
តារាងទី២៖ បញ្ជីនាមក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវានៅក្នុង វិស័យ មូលបត្រ ........................ ៣៤
តារាងទី៣៖បញ្ជីនាមក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យផ្តល់សេវាក្នុងវិស័យ មូលបត្រ ........................ ៣៧
តារាងទី៤៖ បញ្ជីឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ........................ ៣៨
តារាងទី៥៖បញ្ជីនាមភ្នាក់ងារមូលបញ្ញិការមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ........................ ៤១
តារាងទី៦៖លក្ខខណ្ឌតម្រូវក្នុងទីផ្សារគោល ........................ ៤៧
តារាងទី៧៖លក្ខខណ្ឌតម្រូវក្នុងទីផ្សារកំណើន ........................ ៤៩

# បញ្ជីរូបភាព

រូបភាពទី១៖ យន្តការទីផ្សារដំបូង ............ ១០
រូបភាពទី២៖តួអង្គសំខាន់ៗទាំងបួនក្នុងទីផ្សារមូលបត្រ ............ ១២
រូបភាពទី៣៖ រូបសញ្ញាគណៈកម្មការមូលបត្រកម្ពុជា ............ ១៧
រូបភាពទី៤៖ ត្រាគណៈកម្មការមូលបត្រកម្ពុជា ............ ១៨
រូបភាពទី៥៖ រចនាសម្ព័ន្ធគ្រប់គ្រងគណៈកម្មាការមូលបត្រកម្ពុជា ............ ២១
រូបភាពទី៦៖ ការបោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ ............ ២៧
រូបភាពទី៧៖ ភ្នាក់ងារបញ្ជីការមូលបត្រ ............ ៤០
រូបភាពទី៨៖ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ............ ៤០
រូបភាពទី៩៖ ភ្នាក់ងារទូទាត់ ............ ៤២
រូបភាពទី១០៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង របស់ រ.ទ.ស.ភ ............ ៥៤
រូបភាពទី១១៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូងរបស់ ហ.ធ.អ ............ ៥៧
រូបភាពទី១២៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូងរបស់ ក.ស.ភ ............ ៦០
រូបភាពទី១៣៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុនិងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង របស់PPSP ............ ៦៤
រូបភាពទី១៤៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូងរបស់ ក.ស.ស ............ ៦៧

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

វិស័យហិរញ្ញវត្ថុ គឺជាសរសៃឈាមសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ ទស្សនៈវិស័យនេះ នៅឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ «ចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០១ ដល់ ២០១០» និងត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទៅជា «យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១១ ដល់ ២០២០» ។ជាលទ្ធផល សមិទ្ធិផលគួរអោយកត់សម្គាល់ក្នុងរយៈពេលកន្លងមក បានលេចជារូបរាងឡើងដែលរួមមានការពង្រីក និងពង្រឹងប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង និងភតិសន្យាជាដើម។ ដោយសារល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈខ្លាំងក្លា ការធ្វើទំនើបនីយកម្ម និងការធ្វើសុខដុមនីយកម្មនៃវិស័យហិរញ្ញវត្ថុ គឺជាការចាំបាច់ដើម្បីគាំទ្រកំណើននេះឱ្យ មានចីរភាព។ ក្នុងគោលដៅនេះ និម្មាបនិកម្មនៃវិស័យមូលបត្រជាការបំពេញបន្ថែម និងធ្វើឱ្យកាន់តែនេះនឹងធ្វើឱ្យមធ្យោបាយនៃការកៀរគរមូលនិធិ និងការបែងចែកមូលនិធិនៅកម្ពុជាកាន់តែសម្បូរបែបសម្រាប់គម្រោងវិនិយោគនានាដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។

យ៉ាងណាមិញវិស័យមូលបត្រនៅកម្ពុជាកំពុងតែរីកដុះដាល និងដាក់ដំណើរការជួញដូរមកអស់រយៈពេលជាងប្រាំឆ្នាំមកហើយ ដែលក្នុងនោះក៏មានក្រុមហ៊ុនធំៗមួយចំនួនបានចុះបោះផ្សាយលក់មូលបត្រ ព្រមទាំងវិនិយោគិនមួយចំនួនទៀតដែលបានជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាផងដែរ។ ប៉ុន្តែក៏នៅមានប្រជាជនមួយចំនួន សហគ្រាសតូចធំខ្លះទៀតដែលមិនទាន់យល់ដឹង និងជ្រាបច្បាស់ចំពោះវិស័យមូលបត្រនេះ ថាការវិនិយោគលើវិស័យមូលបត្រមានលក្ខណៈយ៉ាងដូចម្តេច តើវិនិយោគិនអាចទទួលអត្ថប្រយោជន៍អ្វីខ្លះ? និងជាពិសេសគឺការចាប់ផ្តើមដំណើរនៃការបោះផ្សាយមូលបត្រត្រូវរៀបចំដោយរបៀបណា មុននឹងបោះផ្សាយលក់បាននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ហេតុដូចនេះហើយទើបបានជាយើងខ្ញុំជ្រើសរើសយកប្រធានបទដែលស្តីពី «**ដំណើរការបោះផ្សាយមូលបត្រកម្មនៅកម្ពុជា**» មកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងគោលបំណងដើម្បីជួយផ្តល់ជាចំណេះដឹងមួយផ្នែកតូចសំរាប់បណ្តាសិស្សានុសិស្សដែលមានបំណងចង់ក្រេបយកចំណេះដឹងខាងផ្នែកមូលបត្រ ក៏ដូចជាពត៌មានបន្ថែមសំរាប់សាធារណៈជនទាំងឡាយអោយស្វែងយល់កាន់ច្បាស់អំពីប្រធានបទនេះ។

## ២. ចំណោទបញ្ហា

ទីផ្សារមូលបត្រ ជាទីផ្សារដែលពុំធ្លាប់មានពីមុនមកក្នុងប្រទេសកម្ពុជា និងជាវិស័យមួយថ្មីដែលកំពុងតែដំណើរការរីកចម្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែក៏នៅមានប្រជាជនមួយចំនួន បណ្តាវិនិយោគិន និងសហគ្រាសតូចធំទាំងឡាយ ក៏នៅមានកម្រិតក្នុងការយល់ដឹងចំពោះវិស័យនេះនៅឡើយ ដែលជាមូលហេតុធ្វើអោយទីផ្សារមូលបត្រក្នុងប្រទេសកម្ពុជាមិនទាន់មានសន្ទុះខ្លាំងដូចជាទីផ្សារមូលបត្រដូចប្រទេសនានាដទៃទៀត។ ជាកិច្ចចំបងយើងគួរយល់ដឹងថាៈ

«កិច្ចដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូងជាសាធារណៈ(IPO)នៅកម្ពុជាមានលក្ខណៈយ៉ាងដូចម្តេច?»

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា**» គឺយើងខ្ញុំចង់ធ្វើការសិក្សាស្វែងយល់ទៅលើចំនុចមួយចំនួនដូចខាងក្រោមៈ

- ស្វែងយល់ពីអត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ច
- ស្វែងយល់ពីតួអង្គសំខាន់ៗ និងធាតុផ្សំដែលមាននៅក្នុងទីផ្សារមូលបត្រ
- ស្វែងយល់ពីយន្តការក្នុងការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈនៅកម្ពុជា
- ស្វែងយល់ពីស្ថានភាព និងរចនាសម្ព័ន្ធរបស់ គណៈកម្មាមូលបត្រនៃកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ «**ដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា**» យើងខ្ញុំសង្កត់ធ្ងន់ចំពោះកិច្ចដំណើរការ( IPO) និងបណ្តាតួអង្គសំខាន់ដែលជាប់ពាក់ព័ន្ធនឹង( IPO) តែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីអោយសារណានេះប្រព្រឹត្តិទៅបានយ៉ាងជោគជ័យ យើងខ្ញុំប្រើវិធីសាស្ត្រពីរយ៉ាងក្នុងការស្រាវជ្រាវគឺៈ

- ទិន្នន័យចម្បងៈ ទិន្នន័យទាំងអស់នេះបានមកតាមរយៈ...
    - ការចុះកម្មសិក្សាផ្ទាល់នៅគណៈកម្មាការមូលបត្រកម្ពុជា

    - ការសាកសួរពត៌មាន និងបានសិក្សាបន្ថែមពីសំណាក់ មន្ត្រី គ.ម.ក ដែលបានបម្រើការនៅក្នុងនាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងផ្សព្វផ្សាយ អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ។
    - ការពន្យល់ណែនាំ និងផ្តល់យោបល់ពីសាស្ត្រាចារ្យណែនាំ។
- ទិន្នន័យបន្ទាប់បន្សំ៖ ទិន្នន័យទាំងអស់នេះបានមកតាមរយៈ...
    - ឯកសារបាយការណ៍របស់រាមច្បងជំនាន់មុន
    - ឯកសារបន្ថែមដែលទាក់ទងនឹងប្រធានបទ សេចក្តីប្រកាស ច្បាប់ អនុក្រឹត្យ និងពុទ្ធិមូលបត្រ នៅក្នុង គណៈកម្មាការមូលបត្រកម្ពុជា
    - គេហទំព័ររបស់គណៈកម្មាការមូលបត្រកម្ពុជា(គ.ម.ក) និងផ្សារមូលបត្រកម្ពុជា(ផ.ម.ក)។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះអាចនឹងផ្តល់ជាអត្ថប្រយោជន៍មួយសំរាប់និស្សិត និងបណ្តាវិនិយោគិនដែលមានបំណងចង់ស្វែងយល់អំពីវិស័យមូលបត្រក្នុងប្រទេសកម្ពុជា ក៏ជាទុនមួយសំរាប់បុគ្គលដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវទៅលើវិស័យមូលបត្រ និងជាមាគ៌ាឈានទៅរកការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀតវាអាចជាជំនួយមួយជួយអោយអ្នកស្រាវជ្រាវអាចផ្សារភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តិថែមទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានចែកចេញជា បីជំពូក ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

### ជំពូកទី១៖ រំលឹកទ្រឹស្តីទីផ្សារមូលបត្រនៅកម្ពុជា

នៅក្នុងជំពូកនេះ នឹងធ្វើការរៀបរាប់ពីនិយមន័យនៃមូលបត្រ និងទីផ្សារមូលបត្រផលប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ តួអង្គដែលជាប់ពាក់ព័ន្ធនិងចូលរួមក្នុងទីផ្សារមូលបត្រនៅកម្ពុជា។

### ជំពូកទី២៖ គណៈកម្មាការមូលបត្រកម្ពុជា

នៅក្នុងជំពូកនេះ នឹងធ្វើបកស្រាយពីស្ថានភាព ប្រវត្តិនៃគណៈកម្មាមូលបត្រនៅកម្ពុជា ចក្ខុវិស័យ បេសកកម្ម មុខងារ សមាសភាព និងរចនាសម្ព័ន្ធនានានៅក្នុង គ.ម.ក ។

## ជំពូកទី៣៖ ដំណើរការបោះផ្សាយមូលបត្រនៅកម្ពុជា

នៅក្នុងជំពូកនេះផងដែរ យើងនឹងធ្វើការពិនិត្យពិច័យ និងយល់ដឹងអំពីកិច្ចដំណើរការបោះផ្សាយតួអង្គដែលចូលរួមក្នុងកិច្ចដំណើរការ ការចុះបញ្ជី និងយន្តការក្នុងការរៀបចំធ្វើ (IPO)មុននឹងឈានទៅរកការជួញដូរនៅទីផ្សារបន្ទាប់។

# ជំពូកទី១

# រំលឹកទ្រឹស្តីវិស័យមូលបត្រនៅកម្ពុជា

## ១.១. និយមន័យមូលបត្រ

មូលបត្រ គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុន ឬជាគំរូមួយលក់ជាសាធារណៈលើការដោះដូរ ឬលើទីផ្សារមូលបត្រ និងទទួលស្គាល់ដោយវិស័យណាមួយដែលវិស័យនោះ មូលបត្រ ត្រូវបានបោះចេញ និងត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើអោយការវិនិយោគ។

## ១.២ ប្រភេទនៃមូលបត្រ

យោងទៅតាមច្បាប់ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧ មូលបត្រចែកចេញជាពីរប្រភេទគឺៈ មូលបត្ររដ្ឋ និងមូលបត្រមហាជន។

### ១.២.១ មូលបត្ររដ្ឋ

មូលបត្ររដ្ឋ គឺជាប័ណ្ណឬសញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរដ្ឋាភិបាលនៅក្រោមច្បាប់ស្តីពីមូលបត្ររដ្ឋ ដោយរួមមានៈ

ក. ប័ណ្ណរតនាគាដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ

ខ. សញ្ញាប័ណ្ណរតនាគាដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ

គ.សញ្ញប័ណ្ណដែលផលចំណូលផ្សារភ្ជាប់និងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។

ឃ. មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារមូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រដែលបោះផ្សាយដោយអាជ្ញាធរ ខេត្ត-ក្រុង និងសហគ្រាស-សាធារណៈ ឬការសុំខ្ចីផ្សេងៗរបស់រដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់ស្តីអំពីមូលបត្ររដ្ឋទេ[1]។

### ១.២.២ មូលបត្រមហាជន

មូលបត្រមហាជន ជាមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀត ដែលបានអនុញ្ញាតិអោយបោះផ្សាយលក់មូលបត្រជាសាធារណៈ

[1] http://www.acledasecurities.com.kh/as/khm/md_securitiesdictionary

នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់។ មូលបត្រទាំងនោះមាន៖ មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ។

**ក. មូលបត្រកម្មសិទ្ធិ**

មូលបត្រកម្មសិទ្ធិ គឺជាប្រភេទមួយនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។ នៅពេលដែលសាធារណជនសម្រេចចិត្តវិនិយោគលើមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ មានន័យថាអ្នកដែលវិនិយោគទិញកម្មសិទ្ធិមួយផ្នែកក្នុងក្រុមហ៊ុននោះ ដែលត្រូវបានគេស្គាល់ថាជាភាគហ៊ុន។ មូលបត្រកម្មសិទ្ធិទទួលបានការចាប់អារម្មណ៍ខ្លាំងពីសាធារណជន ជាពិសេសចំពោះអ្នកមិនសូវមានជំនាញក្នុងការវិនិយោដូចវិនិយោគិនអាជីព ឬវិនិយោគដែលជាស្ថាប័នផ្សេងៗ[2]។

**មូលបត្រកម្មសិទ្ធិមាន ២ ប្រភេទគឺ៖**

**ភាគហ៊ុនធម្មតា៖** ជាប្រភេទភាគហ៊ុនដែលតំណាងអោយភាពជាម្ចាស់កម្មសិទ្ធិលើក្រុមហ៊ុនសាជីវកម្មណាមួយដែលបោះផ្សាយលក់។ ភាពជាម្ចាស់នេះនឹងផ្តល់អោយភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោតក្នុងការចាត់ចែងក្រុមហ៊ុន និងប្រាក់ចំណេញ ឬភាគលាភទៅតាមចំនួនភាគហ៊ុនដែលបានកាន់កាប់។ អ្នកកាន់កាប់ភាគហ៊ុនធម្មតានេះ នឹងទទួលបានការទូទាត់ក្រោយអ្នកកាន់កាប់មូលបត្រផ្សេងៗទៀតរបស់ក្រុមហ៊ុនដូចជាសញ្ញាបណ្ណ និងភាគហ៊ុនបុរិមា។

**ភាគហ៊ុនបុរិមា៖** ជាភាគហ៊ុនទាំងឡាយណា ដែលអ្នកកាន់កាប់មានសិទ្ធិទទួលបានការបែងចែកភាគលាភមុនភាគហ៊ុនធម្មតា និងទទួលបានចំណូលថេរ។ អ្នកកាន់កាប់ភាគហ៊ុនបុរិមានេះមិនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនដូចអ្នកកាន់កាប់ភាគហ៊ុនធម្មតានោះទេ។

**ខ. មូលបត្របំណុល**

មូលបត្របំណុល ឬសញ្ញាបណ្ណ សំដៅលើឧបករណ៍បំណុលរយៈពេលវែង ដែលបានបោះផ្សាយក្នុងជាមូលបត្រ ដោយរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលផ្សេងៗដូចជា សាលាក្រុង សំរាប់បញ្ជាក់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលណាមួយដែលបានអោយប្រាក់ខ្ចី។ សញ្ញាណបណ្ណមួយគឺជាការសន្យារបស់រដ្ឋាភិបាល ឬក្រុមហ៊ុនបោះផ្សាយ ជាមួយអ្នកទិញថានឹងសងត្រឡប់មកវិញនូវចំនួនទឹកប្រាក់ដែលបានខ្ចី ដែលក្នុងន័យបច្ចេកទេស ត្រូវបានគេស្គាល់ថាជាប្រាក់ដើម(Principal amount) រួមទាំងមានការបញ្ជាក់ច្បាស់អំពីអត្រាការប្រាក់ (Interest or coupon) ទឹកប្រាក់ដែលបាន

[2] បៀន សាំង, *មូលបត្រកម្មសិទ្ធិ និងតម្លៃ*, ២០១២, ១២

ខ្ចី និងរយៈពេលដែលត្រូវទទួលបានប្រាក់ដើមមកវិញ។ ជាទូទៅសញ្ញាបណ្ណផ្តល់នូវចំណូលថេរជាក់លាក់មួយដល់វិនិយោគ ព្រោះបរិមាណនៃចំណូលដែលបានមកពីការទិញសញ្ញាបណ្ណគឺថេរដោយសារតែវាមានបញ្ជាក់ពីអត្រាការប្រាក់រួចជាស្រេច។

អ្នកទិញសញ្ញាបណ្ណអាចទទួលបានការប្រាក់របស់ខ្លួនពីក្រុមហ៊ុនបោះផ្សាយបានត្រូវមានបណ្ណបញ្ជាក់ដែលគេអោយឈ្មោះថា Coupon ដែលមានបញ្ជាក់ពីអត្រាការប្រាក់ត្រូវទទួលបាន។ អ្នកទិញត្រូវយក Coupon ទៅបង្ហាញភ្នាក់ងារទូទាត់នៃក្រុមហ៊ុនបោះផ្សាយដើម្បីដកយកការប្រាក់របស់ខ្លួន។ ជាទូទៅសញ្ញាបណ្ណមានពីរប្រភេទគឺសញ្ញាបណ្ណដែលបានបោះផ្សាយដោយរដ្ឋាភិបាល ឬអាជ្ញាធររាជធានី-ខេត្ត (Municipal Bonds) និងសញ្ញាបណ្ណដែលបានបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម (Corporate Bonds)[3] ។

មូលបត្របំណុលរួមមាន[4]៖

**ក. សញ្ញាបណ្ណ៖** ជាមូលបត្របំណុលដែលចេញដោយរដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម។ ជាទូទៅអ្នកចេញផ្សាយលក់សញ្ញាបណ្ណចុះកិច្ចសន្យាត្រូវទូទាត់ការប្រាក់ និងប្រាក់ដើមនៅកាលបរិច្ឆេទជាក់លាក់ និងអត្រាការប្រាក់ជាក់លាក់។

**ខ. បណ្ណរតនាគាររយៈពេលខ្លី៖** ជាប្រភេទមូលបត្ររយៈពេលខ្លីចេញផ្សាយដោយរដ្ឋាភិបាល។ ជាទូទៅអ្នកដែលវិនិយោគលើ T-bills មិនទទួលបានការប្រាក់ទេ ប៉ុន្តែពួកគេអាចទទួលបាននូវប្រាក់ចំណេញពីការទិញក្នុងតំលៃអប្បហារ (Discount)។

**គ. វិញ្ញាបនបត្រប្រាក់បញ្ញើ៖** គឺជាប្រភេទវិនិយោគធំៗ ជាពិសេសក្រុមហ៊ុនសាជីវកម្មធំៗដាក់តម្កល់មូលនិធិរបស់ខ្លួននៅក្នុងធនាគារពាណិជ្ជ ឬស្ថាបនទទួលបញ្ញើដទៃទៀត ដែលមានកាលកំណត់ជាក់លាក់ច្បាស់លាស់ជាទូទៅគឺមានរយៈពេល៣ឆ្នាំ។

**ឃ. សញ្ញាបណ្ណចែករំលែកប្រាក់ចំណេញ៖** ជាប្រភេទសញ្ញាបណ្ណដែលផ្តល់ទាំងអត្រាការប្រាក់ថេរ និងចំណែកនៃប្រាក់ចំណេញដល់អ្នកវិនិយោគដែលកាន់កាប់សញ្ញាបណ្ណនេះទៀតផងនៅក្នុងទំហំមួយដែលបានចែងក្នុងកិច្ចសន្យាទិញសញ្ញាបណ្ណ។

---

[3] http://thachcenter.com/10/

[4] បៀន សាំង, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*,២០១១,២៩

**ង. សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ៖** សំដៅលើសញ្ញាបណ្ណដែលបានបោះផ្សាយលក់ក្នុងថ្លៃអប្បហារ នៃតម្លៃចារឹករបស់សញ្ញាបណ្ណ។

**ច. សញ្ញាបណ្ណដែលអាចប្តូរបាន៖** ជាសញ្ញាបណ្ណដែលអាចប្តូរទៅជាភាគហ៊ុនធម្មតាបានក្នុងករណីអ្នកវិនិយោគចង់ផ្លាស់ប្តូរដោយមានការព្រមព្រៀងពីក្រុមហ៊ុន។

**ឆ. សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់៖** ជាសញ្ញាបណ្ណទាំងឡាយណាដែលត្រូវបានវាយតម្លៃនៅក្រោមកម្រិតវិនិយោគ ដើម្បីបង្ហាញថាសញ្ញាបណ្ណណាដែលមានទិន្នផល ឬអត្រាការប្រាក់ខ្ពស់ដល់វិនិយោគិន។

**ជ. សញ្ញាបណ្ណធានា៖** ផ្តល់សិទ្ធិអោយអ្នកវិនិយោគក្នុងការទិញភាគហ៊ុននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតក្នុងតម្លៃជាក់លាក់មួយ។

**ឈ. សញ្ញាបណ្ណសន្ទស្សន៍ថ្លៃ៖** ជាទូទៅត្រូវបានប្រើប្រាស់ក្នុងពេលដែលមានអតិផរណាខ្ពស់ហើយការទូទាត់ការប្រាក់នៃសញ្ញាបណ្ណនេះ ត្រូវបានធ្វើជាតារាងរៀងទៅតាមអត្រាអតិផរណា។

**ញ. ផលបត្រពាណិជ្ជកម្ម៖** ត្រូវបានបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មនិងមានកាលបរិច្ឆេទតណាប្រតិទានមិនលើសពី១ឆ្នាំ។

**ដ. មូលបត្រដាក់បញ្ចាំ៖** ជាមូលបត្រដែលត្រូវបានធានាដោយការដាក់បញ្ចាំភ្ជាប់មកជាមួយក្នុងករណីដែលកូនបំណុលមិនអាចមានលទ្ធភាពទូទាត់បំណុលបាន នោះម្ចាស់បំណុលមានសិទ្ធិលក់ទ្រព្យសកម្មនោះដើម្បីទូទាត់បំណុលដែលមាន។

**គុណសម្បត្តិនៃមូលបត្របំណុល ឬសញ្ញបណ្ណ៖**

១. អ្នកកាន់កាប់សញ្ញាបណ្ណ ពុំទទួលរងហានិភ័យខ្ពស់ដូចជាអ្នកកាន់កាប់បណ្ណភាគហ៊ុនទេ ព្រោះអ្នកកាន់កាប់សញ្ញាបណ្ណ មិនទទួលរងហានិភ័យនៅពេលក្រុមហ៊ុនខាតបង់។

២. អ្នកកាន់កាប់សញ្ញាបណ្ណមិនចូលរួមខាតបង់ ទោះបីជាក្រុមហ៊ុនមិនទទួលបានប្រាក់ចំណេញក៏ដោយ។

៣. អ្នកកាន់កាប់សញ្ញាបណ្ណអាចទាមទារការទូទាត់ពេញលេញ (សងមកវិញទាំងប្រាក់ដើម និងការប្រាក់ទាំងអស់) បើទោះជាក្រុមហ៊ុនប្រឈមមុខនឹងការក្ស័យធន(Bankruptcy) ក៏ដោយ។

៤. ផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុនក្នុងការកៀរគរមូលធនបន្ថែម។

**គុណវិបត្តិនៃមូលបត្របំណុល ឬសញ្ញាបណ្ណ៖**

១. អ្នកកាន់កាប់សញ្ញាបណ្ណ មិនទទួលបានសិទ្ធិពីការចែកភាគលាភ និងសិទ្ធិបោះឆ្នោតពីក្រុមហ៊ុន។

២. ក្រុមហ៊ុបោះផ្សាយត្រូវទទួលសងអ្នកកាន់កាប់សញ្ញាបណ្ណ បើទោះជាក្រុមហ៊ុនប្រឈមមុខនឹងការក្ស័យធន(Bankruptcy) ក៏ដោយ[5]។

**គ. ឧបករណ៍និស្សន្ទ ឬដេរីវេទីវ**

ជាកិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅអោយបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញលក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគតដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រាស់សិទ្ធិនេះក៏ដោយ។ មូលបត្រដេរីវេរួមមាន៖

**ក. Options**

គឺជាសិទ្ធិតែមិនមែនជាកាតព្វកិច្ចក្នុងការទិញ ឬលក់ទ្រព្យក្នុងតម្លៃកំណត់មួយនៅកាលបរិច្ឆេទមួយកំណត់។ Option ត្រូវបានចែកចេញជា Call option និង Put option។ Call option ផ្តល់សិទ្ធិក្នុងការទិញទ្រព្យសកម្ម ក្នុងថ្លៃកំណត់មួយព្រមព្រៀងលើកិច្ចសន្យា នៅកាលបរិច្ឆេទកំណត់ហៅថា Exercise price ឬStrike price។ ចំណែកឯ Put option ផ្តល់ជូននូវសិទ្ធិក្នុងការលក់ទ្រព្យសកម្ម លើថ្លៃកំណត់មួយនៅកាលបរិច្ឆេទកំណត់ជាក់លាក់មួយ។

**ខ. Forward**

ជាកិច្ចសន្យាដែលក្នុងនោះគេអាចទិញ ឬលក់បរិមាណទំនិញ ឬផលិតផលដែលកំណត់ថ្លៃនិងបរិមាណនៅថ្ងៃនេះហើយប្រតិបត្តិការគឺនឹងត្រូវធ្វើនៅពេលក្រោយ។

**គ. Future Contract**

ជាកិច្ចសន្យាហិរញ្ញវត្ថុដែលតម្រូវអោយអ្នកទិញធ្វើការទិញ ឬក្នុងករណីអ្នកលក់ ធ្វើការលក់ទ្រព្យសម្បត្តិស្ថិតនៅក្រោមកិច្ចសន្យា នៅកាលបរិច្ឆេទដែលជាក់លាក់មួយនៅពេលអនាគត។

**ឃ. Swaps**

សំដៅលើការដោះដូរមូលបត្រ រូបិយវត្ថុ ឬអត្រាការប្រាក់។

[5] http://thachcenter.com/10/

## ១.៣ ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រគឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន "សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬស្នើការទិញ លក់មូលបត្រ" ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម[6]។

### ១.៣.១ ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីផ្សារទ្រព្យសកម្ម ដែលនៅទីនោះមូលបត្រត្រូវបានបោះផ្សាយ និងលក់ជាលើកដំបូងតាមរយៈការធ្វើសំណើរទិញ ឬដំណើរការដេញថ្លៃ។ ទីផ្សារដំបូងត្រូវបានជួយសម្រួលដោយសម្ព័ន្ធក្រុមហ៊ុនធានាទិញមូលបត្រដែលរួមមាន ធនាគារ វិនិយោគ ដែលនឹងដាក់តម្លៃដេញថ្លៃដំបូងក្នុងចន្លោះណាមួយសម្រាប់មូលបត្រណាមួយ។

**<u>យន្តការទីផ្សារដំបូង</u>**

**<u>រូបភាពទី១</u>៖** យន្តការទីផ្សារដំបូង




ប្រភព៖ ឯកសារស្វែងយល់ពីទីផ្សារមូលបត្រកម្ពុជា

[6] ច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន ដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលាឆ្នាំ២០០៧

### ១.៣.២ ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ គឺជាទីផ្សារសំរាប់ជួញដូរមូលបត្រដែលបានបោះផ្សាយរវាង វិនិយោគិនសាធារណៈ និងវិនិយោគិនសាធារណៈ។ វិនិយោគិនដែលទិញភាគហ៊ុននៅទីផ្សារដំបូង ហើយចង់លក់ភាគហ៊ុននោះចេញដើម្បីយកសាច់ប្រាក់មកវិញ ត្រូវលក់ភាគហ៊ុននោះទៅអោយវិនិយោគិនដទៃទៀតដែលចង់ទិញភាគហ៊ុនរបស់ខ្លួន គឺមិនមែនលក់ទៅអោយក្រុមហ៊ុនបោះផ្សាយវិញទេ។ ការទិញលក់តទៅនេះ រវាងវិនិយោគិន (អ្នកទិញ) និងវិនិយោគិន (អ្នកលក់) ត្រូវបានគេហៅថា ជាការទិញលក់នៅលើទីផ្សារបន្ទាប់ គឺប្រៀបបាននឹងការជួញដូរវត្ថុ "ជជុះ" រវាងអ្នកប្រើប្រាស់ដូចគ្នាដូច្នោះដែរ គ្រាន់តែភាគហ៊ុនមិនចេះសឹករិចរឹលប៉ុណ្ណោះ។ ការជួញដូរនៅទីផ្សារបន្ទាប់គឺធ្វើឡើងនៅក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា (ផ.ម.ក)។ ផ.ម.ក មានតួនាទីចម្បងក្នុងការផ្តល់សេវាទីកន្លែង និងប្រព័ន្ធជួញដូរ សម្រាប់វិនិយោគិនងាយស្រួលរកគ្នាឃើញ (អ្នកលក់និងអ្នកទិញដើម្បីជួញដូរជាមួយគ្នា)។

## ១.៤ តួអង្គសំខាន់ៗទាំង ៤ ក្នុងទីផ្សារមូលបត្រ (4Is)

ទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុស៊ីជម្រៅ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រហូតមកដល់ពេលនេះ អត្ថិភាពនៃអង្គ ៤ ជាសារវន្តដែលគាំទ្រដល់ដំណើរការនៃទីផ្សារមូលបត្រ ត្រូវបានកសាងជាបន្តបន្ទាប់រួមមាន[7]៖

**ហេដ្ឋារចនាសម្ព័ន្ធ(Infrastructure)៖** សំដៅដល់បទដ្ឋានគតិយុត្តផ្សេងៗដូចជាច្បាប់ បទប្បញ្ញត្តិ ដែលបង្កើតឡើងដោយនិយ័តករមូលបត្រ ដើម្បីគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព សមធម៌ តម្លាភាព និងទូទាត់មូលបត្រផងដែរ។ នាពេលបច្ចុប្បន្ននេះមូលបត្រភាគច្រើនមិនមែនជាក្រដាសដូចកាលពីសម័យមុននោះទេ។ មូលបត្រត្រូវបានកត់ត្រា រក្សាទុក និងជួញដូរនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាកុំព្យូទ័រទាំងអស់។ នៅកម្ពុជា និយ័តករមូលបត្រដែលបង្កើតបទដ្ឋានគតិយុត្តទីផ្សារមូលបត្រនោះគឺ **គណៈកម្មការមូលបត្រកម្ពុជា** (គ.ម.ក)។ ចំណែកឯប្រព័ន្ធជួញដូរ រក្សាទុក និងផាត់ទាត់ និងទូទាត់មូលបត្រត្រូវបានផ្តល់ដោយ **ក្រុមផ្សារមូលបត្រកម្ពុជា**។

**អន្តរការី(Intermediary)៖** អន្តរការីមានតួនាទីជួយសម្របសម្រួលផ្តល់ប្រឹក្សាជូនដល់ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ ព្រមទាំងធានាឲ្យបាននូវការបោះផ្សាយលក់មូលបត្រ ដែលប្រកបដោយជោគជ័យ។ ជាពិសេស អន្តរការីធ្វើទំនាក់ទំនងផ្តល់ប្រឹក្សា ក៏ដូចជាផ្តល់

[7] *ពុទ្ធិមូលបត្រស្តីពីតួអង្គសំខាន់ៗទាំង៤ក្នុងទីផ្សារមូលបត្រ4Is* លេខVIIចេញផ្សាយប្រចាំសប្តាហ៍ទី២ ខែតុលា ២០១៦

មធ្យោបាយជួញដូរ ដល់វិនិយោគិនផងដែរ។ បើគ្មានអន្តការីនោះទេ នោះពុំមានស្ពានតភ្ជាប់ក្រុមហ៊ុនបោះផ្សាយ ទៅកាន់និយ័តករ និងផ្សារមូលបត្រនោះឡើយ ហើយក៏គ្មានអ្នកទាក់ទាញវិនិយោគិនទិញនោះឡើយ ហើយក៏គ្មានអ្នកទាក់ទាញវិនិយោគិនទិញមូលបត្រជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែរ។

**ក្រុមហ៊ុនបោះផ្សាយ(Issuer)៖** តួអង្គសំខាន់បំផុតមួយទៀតក្នុងទីផ្សារមូលបត្រ គឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ព្រោះប្រសិនបើគ្មានក្រុមហ៊ុនបោះផ្សាយទេក៏គ្មានក្រុមហ៊ុនមូលបត្រសម្រាប់លក់ និងជួញដូរនៅទីផ្សារដែរ។ តួអង្គដ៏សំខាន់របស់ទីផ្សារមូលបត្រគឺជួយផ្តល់ដើមទុនបន្ថែមដល់ក្រុមហ៊ុនបោះផ្សាយ ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

**វិនិយោគិន(Investor)៖** វិនិយោគិនជាតួអង្គសំខាន់មួយក្នុងចំណោមតួអង្គទាំងបួន ព្រោះបើគ្មានវិនិយោគិន ក៏បោះផ្សាយលក់ និង/ឬជួញដូរមូលបត្រមិនជោគជ័យដែរ។ វិនិយោគិន សំដៅដល់សាធារណជនទូទៅ ឬស្ថាប័នដែលបានទិញមូលបត្រ។

សម្រាប់ទីផ្សារមូលបត្រដែលល្អបរិបូរណ៍ ការណ៍មានតែបួនតួអង្គនេះ គឺមិនគ្រប់គ្រាន់នោះទេ។ វាទាមទារឲ្យមានតួអង្គបន្ទាប់បន្សំជាច្រើនទៀត ដែលកម្ពុជាបាន និងកំពុងរៀបចំបទដ្ឋានគតិយុត្តិ ដើម្បីដាក់ឲ្យដំណើរការជាបន្តបន្ទាប់។ **គំនូសបំព្រួញនៃតួអង្គសំខាន់ៗ4Is៖**

**<u>រូបភាពទី២</u>៖** តួអង្គសំខាន់ៗទាំង៤ក្នុងទីផ្សារមូលបត្រ(4Is)




ប្រភព៖ ពុទ្ធិមូលបត្រស្តីពីតួអង្គសំខាន់ៗទាំង៤ក្នុងទីផ្សារមូលបត្រ

## ១.៥ អត្ថប្រយោជន៍ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាសរសៃឈាមដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ វិនិយោគិននានាក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។ អាស្រ័យហេតុនេះ គ្រប់ប្រទេសទាំងអស់នៅលើពិភពលោកតែងតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍទីផ្សារនេះ ដើម្បីធានាបាននូវការ

អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និង ចីរភាព ក្នុងទិសដៅរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។

ក្នុងរយៈពេលជាងមួយទស្សវត្សរ៍កន្លងទៅ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងអត្រាប្រមាណ ៨,៥ភាគរយ ក្នុងមួយឆ្នាំ ទោះជាត្រូវជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យជាច្រើនទាំងក្នុង និងក្រៅប្រទេសយ៉ាងណាក៏ដោយ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នសកលចាត់ទុកកម្ពុជាថាជាប្រទេសមួយនៅក្នុងចំណោមប្រទេសប្រាំបីដែលមានភាពធន់នៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត។

ការសម្រេចបាននូវសមិទ្ធិផលទាំងអស់នេះ បានរុញច្រានកម្ពុជាអោយមកដល់ខ្ពង់រាបថ្មីមួយទៀត គឺឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ ដែលកំពុងប្រែក្លាយកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយកម្ពុជាត្រូវធានាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ សម្រាប់ជាមូលដ្ឋាននៃការបង្កើតការងារនិងឱកាសរកប្រាក់ចំណូលសមរម្យ។

ក្នុងន័យនេះ វិស័យមូលបត្រត្រូវបានអភិវឌ្ឍ និងដើរតួជាមធ្យោបាយនៃការកៀរគរមូលធន និងការបែងចែកមូលធននៅកម្ពុជាអោយកាន់តែសម្បូរបែប សម្រាប់គម្រោងវិនិយោគនានា ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។

រហូតមកដល់ពេលនេះ ហេដ្ឋារចនាសម្ព័ន្ធ គន្លឹះនៃទីផ្សារមូលបត្រត្រូវបានដាក់អោយដំណើរការជាបន្តបន្ទាប់ ដែលក្នុងនោះរួមមាន ហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត ប្រព័ន្ធប្រតិបត្តិការ អ្នកចូលរួមក្នុងទីផ្សារ វិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាដើម។

ការអភិវឌ្ឍទីផ្សារមូលបត្រនឹងនាំមកនូវអត្ថប្រយោជន៍ដូចតទៅ ៖

**រួមចំណែកដល់កំណើនសេដ្ឋកិច្ច៖** ដំណើរការទិញ លក់ទាំងនេះអាចជួយក្នុងដំណើរការអនុវត្តគម្រោងវិនិយោគដែលមានផលិតភាពខ្ពស់ដែលអាចឈានទៅដល់ការបង្កើតមូលធន និងនាំអោយមានកំណើនសេដ្ឋកិច្ច។ ប្រភពដើមទុន សាច់ប្រាក់ដែលរាយប៉ាយ នឹងត្រូវបានប្រមូលចងក្រងយកទៅប្រើប្រាស់ចំទិសដៅ ហើយផ្តល់ជាប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។ ទីផ្សារមូលបត្រគឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តិន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម។

**ជំរុញការវិនិយោគ និងបង្កើតការងារ៖** តាមរយៈទីផ្សារមូលបត្រ ក្រុមហ៊ុនបោះផ្សាយនឹងមានលទ្ធភាពបង្កើនដើមទុនសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន ដោយទទួលបានដើមទុនច្រើន និងមានរយៈពេលវែង។ បច្ច័យនេះនឹងជំរុញ ព្រមទាំងលើកទឹកចិត្តឱ្យក្រុមហ៊ុនធ្វើការវិនិយោគបន្ថែម ក៏

ដូចជាបន្ថែមតម្រូវការបុគ្គលិកសម្រាប់បំពេញការងារក្នុងស្ថាប័នខ្លួនឯងដែរ។ ក្នុងន័យនេះ អត្រានិកម្មភាពក្នុងប្រទេសក៏នឹងត្រូវបានកាត់បន្ថយផងដែរ ប្រសិនបើក្រុមហ៊ុនមានដើមទុនសម្រាប់ធ្វើការវិនិយោគបន្ថែម។

**ទទួលបានការលើកទឹកចិត្តពន្ធដារ៖** ដោយយល់ដឹងពីអត្ថប្រយោជន៍ និងដើម្បីជំរុញវិស័យមូលបត្រកម្ពុជាឱ្យរីកចម្រើនកាន់តែឆាប់រហ័ស រាជរដ្ឋាភិបាលកម្ពុជាបានចេញ អនុក្រឹត្យពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដោយផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនិងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រ បានជោគជ័យមុនដំណាច់ឆ្នាំ ២០១៧ ឱ្យទទួលបានការអនុគ្រោះបំណុលពន្ធ និងកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន៥០% រយៈពេល៣ឆ្នាំ ព្រមទាំងលើកលែងការបង់ពន្ធរំដោះលើប្រាក់ចំណេញ១%ប្រចាំខែ។ ម្យ៉ាងទៀតវិនិយោគិនក៏ទទួលបានការលើកទឹកចិត្តពន្ធដារកាត់បន្ថយពន្ធលើភាគលាភ ឬការប្រាក់ ៥០% ផងដែរ។

**ធានាស្ថេរភាពអាជីវកម្ម និងកាត់បន្ថយចំណាយប្រតិបត្តិការ៖** ទីផ្សារមូលបត្រនឹងជួយសម្រួល ដល់អាជីវកម្មឱ្យមានភាពយូរអង្វែង ដោយសារទីផ្សារមូលបត្រអនុញ្ញាតិឱ្យក្រុមហ៊ុនកៀរគរ និងប្រមូលទុនបានច្រើនដោយសារប្រើប្រាស់ថ្លៃដើមទាបមានរយៈពេលវែង និងពុំចាំបាច់ជាប់កាតព្វកិច្ចសង ហើយក្រុមហ៊ុនក៏អាចធ្វើការប្រមូលទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្មបានច្រើនដង។ ដូចនេះ ទីផ្សារមូលបត្រគឺជាឧបករណ៍ និងជាមធ្យោបាយដ៏ប្រសើរសម្រាប់ជួយធានាបន្ថែមដល់ស្ថេរភាពអាជីវកម្ម។

**ផ្តល់គុណតម្លៃកេរ្តិ៍ឈ្មោះ និងសុវត្ថិភាពដល់ប្រតិបត្តិការ៖** នៅក្នុងទីផ្សារមូលបត្រ មានតែភាគហ៊ុនដែលបានចុះបញ្ជីតែប៉ុណ្ណោះដែលអាចជួញដូរបាន ហើយគណៈកម្មាការមូលបត្រកម្ពុជាផ្តល់សិទ្ធិឱ្យចុះបញ្ជីសម្រាប់តែក្រុមហ៊ុនណាដែលមានភាពរឹងមាំផ្នែកហិរញ្ញវត្ថុ និងមានគុណវុឌ្ឍគ្រប់គ្រាន់តែប៉ុណ្ណោះ។ ក្រុមហ៊ុនដែលបានចុះបញ្ជីនៅទីផ្សារត្រូវប្រតិបត្តិទៅតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាបាននូវការទទួលស្គាល់កេរ្តិ៍ឈ្មោះ និងប្រសិទ្ធិភាពនៃការគ្រប់គ្រងបានល្អប្រសើរ។

**ចែករំលែកពត៌មានដោយសមធម៌៖** គណៈកម្មការមូលបត្រកម្ពុជាការពារសាធារណៈជនដែលធ្វើការវិនិយោគជាមួយទីផ្សារមូលបត្រ ដោយដាក់កម្រិតលើការបោះផ្សាយភាគហ៊ុនថ្មី ធ្វើអោយការអនុវត្តិន៍ការជួញដូរកាន់តែល្អប្រសើរ និងធ្វើការអប់រំសាធារណៈជនអំពីការវិនិយោគ។ ក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រ ត្រូវបានត្រួតពិនិត្យ ទទួលស្គាល់ និងអនុញ្ញាតិពីគណៈកម្មការមូលបត្រកម្ពុជាដែលជាអាជ្ញាធរមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនបោះ

ផ្សាយត្រូវចេញផ្សាយរបាយការណ៍ទៅតាមពេលវេលាកំណត់ ព្រមទាំងបង្ហាញពត៌មានអំពីសកម្មភាពអាជីវកម្មរបស់ខ្លួន និងអភិបាលកិច្ចសាជីវកម្ម ដើម្បីផ្តល់ទំនុកចិត្តដល់វិនិយោគិន។

**ទទួលបានចំណូលពីការវិនិយោគក្នុងទីផ្សារមូលបត្រ៖** មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើងសម្រាប់កសាងទ្រព្យសម្បត្តិ និងជាផ្នែកមួយនៃការវិនិយោគ។ ភាគហ៊ុនតំណាងឱ្យចំណែកនៃភាពជាម្ចាស់នៃក្រុមហ៊ុនមួយ។ ភាគហ៊ុនតំណាងអោយសិទ្ធិលើទ្រព្យសកម្ម និងប្រាក់ចំណូលរបស់ក្រុមហ៊ុន។ បើអ្នកកាន់កាប់ភាគហ៊ុនកាន់តែច្រើនក្នុងក្រុមហ៊ុនមួយ ភាពជាម្ចាស់របស់អ្នកនៅក្នុងក្រុមហ៊ុននោះក៏កាន់តែធំតាមនោះដែរ។ សារៈសំខាន់នៃការក្លាយជាម្ចាស់ភាគហ៊ុន គឺថាអ្នកមានសិទ្ធិទទួលបានចំណែក នៃប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ប្រាក់ចំណេញនឹងបង់ក្នុងទម្រង់ការឱ្យភាគលាភ ឬការប្រាក់។ បើអ្នកកាន់កាប់ភាគហ៊ុនកាន់តែច្រើន អ្នកនឹងទទួលបានចំណែកនៃការប្រាក់ចំណេញកាន់តែច្រើនតាមនោះដែរ។ ក្នុងនាមជាម្ចាស់ភាគហ៊ុន អ្នកពុំចាំបាច់មានកាតព្វកិច្ចទទួលខុសត្រូវផ្ទាល់នោះទេ នៅពេលក្រុមហ៊ុនមិនអាចសងបំណុលម្ចាស់បំណុលបាន។ ទោះបីជាមានបញ្ហាអ្វីក៏ដោយ តម្លៃអតិបរមាដែលអ្នកអាចបាត់បង់ គឺជាតម្លៃនៃការវិនិយោគរបស់អ្នក។

**ជួយជំរុញទម្លាប់សន្សំ និងវិនិយោគ៖** ទីផ្សារមូលបត្រផ្តល់នូវឱកាសនៃការវិនិយោគដ៏ទាក់ទាញ តាមរយៈភាគហ៊ុនរបស់ក្រុមហ៊ុនជាច្រើនក្នុងទីផ្សារ។ ឱកាសវិនិយោគទាំងនេះ លើកទឹកចិត្តឱ្យប្រជាជនមានការសន្សំច្រើនជាងមុន និងធ្វើការវិនិយោគជាមួយវិស័យមូលបត្រ ជាជាងយកប្រាក់ទៅវិនិយោគជាមួយទ្រព្យដែលគ្មានផលិតកម្ម ដូចជាមាស ឬប្រាក់ជាដើម។ វិស័យមូលបត្រនឹងជួយបំពេញបន្ថែមគុណភាពនៃការសម្រេចចិត្តវិនិយោគរបស់ប្រជាជនខ្មែរ។

**ផ្តល់សន្ទនីយភាព៖** មុខងារដ៏សំខាន់មួយទៀតនៃទីផ្សារមូលបត្រគឺការផ្តល់នូវភាពត្រៀមជាស្រេចសម្រាប់ការលក់ និងការទិញមូលបត្រ។ វត្តមាននៃទីផ្សារមូលបត្រ បានជួយសម្រួលដល់វិនិយោគិនដោយការវិនិយោគរបស់ពួកគេអាចត្រូវបានផ្លាស់ប្តូរជាសាច់ប្រាក់បានគ្រប់ពេល នៅពេលដែលពួកគេត្រូវការ។ វិនិយោគិនអាចវិនិយោគជាមួយគម្រោងវិនិយោគរយៈពេលវែងដោយគ្មានការស្ទាក់ស្ទើរដោយសារគេអាចបំប្លែងការវិនិយោគរយៈពេលវែងនេះទៅជាការវិនិយោគរយៈពេលខ្លី។

# ជំពូកទី២

# គណៈកម្មការមូលបត្រកម្ពុជាមូលបត្រកម្ពុជា

## ២.១ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ជាស្ថាប័នជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិកមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅអ្នកការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាអោយមានឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវក្នុងវិស័យមូលបត្រនៃព្រះរាជណាចក្រកម្ពុជា[8]។

### ២.១.១. ប្រវត្តិគណៈកម្មការទីផ្សារមូលបត្រកម្ពុជា

គ.ម.ក ត្រូវបានបង្កើតឡើងក្រោមបញ្ញត្តិនៃច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលត្រូវបានសម្រេចដាក់អោយដំណើរការជាផ្លូវការកាលពី ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៩ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃគ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្តីពី "ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា" ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៨។

### ២.១.២ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់ គ.ម.ក

#### ២.១.២.១. រូបសញ្ញា

- រូបហង្សពណ៌មាស។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតពណ៌ប្រផេះ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា «**គណៈកម្មការមូលបត្រកម្ពុជា**» និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអងក្សរអង់គ្លេសថា «**SECURITIES AND EXCHANGE COMMISION CAMBODIA**»។

[8] http://www.secc.gov.kh/khmer/faq.php?pn=2

**<u>រូបភាពទី៣</u>៖** រូបសញ្ញាគណៈកម្មការមូលបត្រកម្ពុជា

ប្រភព៖ គេហទំព័រ គណៈកម្មាការមូលបត្រកម្ពុជា

**២.១.២.២. អត្ថន័យនៃរូបសញ្ញា**

- រូបហង្សពណ៌មាស តំណាងអោយអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាអោយដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធិភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះចង់បង្ហាញថាភាពចំណេញខាត ឬ ភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធិភាព សណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-ជាតិ។

**ក. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការអភិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅលើប្រាក់ប្រាសាទក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក សំអាង ហង្ស ដែល ព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុខ្មែរមានសញ្ញាណច្បាស់លាស់ និងដាក់ឱ្យចរាចរក្នុងសេដ្ឋកិច្ច។

- រូបហង្សពណ៌មាសនេះជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម សម័យសាធារណៈរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលការណ៍នេះត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**។

### ខ. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា

<u>***រូបភាពទី៤***</u>៖ ត្រាគណៈកម្មាការមូលបត្រកម្ពុជា



ប្រភព៖ គេហទំព័រ គណៈកម្មាការមូលបត្រកម្ពុជា

ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា « **ព្រះរាជាណាចក្រកម្ពុជា**» ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា «**គណៈកម្មការមូលបត្រកម្ពុជា**» ។

## ២.២ ចក្ខុវិស័យ និង បេសកកម្ម

### ២.២.១. ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួយដូរមូលបត្រមហាជនដែលអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក

ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀងគរមូលធនពីសាធារណៈជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា[៩]។

### ២.២.២. បេសកកម្ម

១. បង្កើត និងរក្សាទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និង ត្រឹមត្រូវ។

២. លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធិភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

៣. ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

៤. ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥. ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៣ មុខងាររបស់ គ.ម.ក

គណៈកម្មការមូលបត្រមានមុខងារដូចខាងក្រោមៈ

១. គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។

២. ដាក់ឱ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។

៣. កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតិជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

៤. កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។

៥. លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។

[9] គេហទំព័រគណៈកម្មការមូលបត្រកម្ពុជាhttp://www.secc.gov.kh

៦. ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាបណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួមឬអ្នកវិនិយោគ។

៧. ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

## ២.៤ សមាសភាពរបស់ គ.ម.ក

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជាជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សមាសភាពរបស់ គ.ម.ក មាន៖

១. តំណាងក្រសួងសេដ្ឋកិច្ច ០១ (មួយ) រូប

២. តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ) រូប

៣. តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ) រូប

៤. តំណាងក្រសួងយុត្តិធម៌ ០១ (មួយ) រូប

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ (មួយ) រូប

៦. អគ្គនាយក **គ.ម.ក** ០១ (មួយ) រូប

៧. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២(ពីរ) រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។ សមាជិក គ.ម.ក ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬច្រើនផ្នែកដូចជាពាណិជ្ជកម្មគ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណនេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង។

## ២.៥ រចនាសម្ព័ន្ធគ្រប់គ្រង គ.ម.ក

រចនាសម្ព័ន្ធត្រូវបានរៀបចំឡើងដើម្បីបែងចែកទំនួលខុសត្រូវលើការងាររបស់បុគ្គលិកម្នាក់ៗទៅតាមផ្នែកនីមួយៗ និងតួនាទីរៀងៗខ្លួន រចនាសម្ព័ន្ធរបស់គ.ម.កគឺ៖

**<u>រូបភាពទី៥</u>៖** រចនាសម្ព័ន្ធគ្រប់គ្រង គណៈកម្មាការមូលបត្រ




ប្រភព៖ គេហទំព័រ គណៈកម្មាការមូលបត្រកម្ពុជា

**នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុមានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការរបស់ គ.ម.ក
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ចាត់ចែងការងារពិធីការ
- ផ្គត់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាពត៌មាន

**នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រមានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈប្រចាំ

- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារ ផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ពត៌មាន ឯកសារពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែង នានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬ/និង តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រលក់ជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមានការចាំបាច់ស្របតាមលក្ខខណ្ឌការងារគ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថាមានប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយ លក់ មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត

**នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ មានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ជាអាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមនៅក្នុងទីផ្សារដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតិពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យនិងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួយជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ

- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុន ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្តែងដល់កន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុនមូលបត្រភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ

**នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតិឲ្យធ្វើប្រតិបត្តិការជាមួយប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីសុំការពិនិត្យ និងអនុញ្ញាតិពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតិ ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់ និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត

**នាយកដ្ឋានគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារនិងតួនាទីដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទបញ្ញត្តិចាំបាច់នានា និងលើកសំណើរធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ អគ្គនាយកនៃគ.ម.ក

**នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារតួនាទីដូចតទៅៈ

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជាសិក្សាស្រាវជ្រាវលើការអភិវឌ្ឍ
- គ្រប់គ្រង និងអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈសិក្សាវាយតម្លៃ និងផ្តល់យោបល់
- រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតិឲ្យបោះផ្សាយនៅលើទីផ្សារ

- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណៈជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា

**អង្គភាពសវនកម្មផ្ទៃក្នុង**

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលឋិតនៅក្រោមការដឹកនាំផ្ទាល់របស់ ប្រធានគ.ម.ក។ អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួនាទីដូចតទៅ៖

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក ក្នុងការិបរិច្ឆេតសមស្រប ដើម្បីកំណត់ការអនុវត្តបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទបញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក
- កំណត់ភាពសមស្រប និងប្រសិទ្ធិភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក
- ពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃពត៌មាន ទិន្និន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីពត៌មាន និងទិន្នន័យទាំងនេះក្នុងការិយបរិច្ឆេតសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការនីតិវិធីច្បាប់និងបទបញ្ញត្តិនានា ហើយលើកសំណើរកែតម្រូវ និងកែលំអរ ប្រសិនបើមានកំហុស
- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធិភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ គ.ម.ក ហើយលើកសំណើរដោះស្រាយ និងកែលំអរការអនុវត្តប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការរបស់ គ.ម.ក ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ

- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើរជូនប្រធាន និងសមាជិក គ.ម.ក ពិនិត្យនិងផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិក នៃគ.ម.ក ពិនិត្យ និងសម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្ម ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និងសមស្របជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

# ជំពូកទី៣

# ដំណើរការបោះផ្សាយមូលបត្រ (IPO)នៅកម្ពុជា

## ៣.១ តើអ្វីទៅជា IPO?

IPO ( Initial Public offering) គឺជាការលក់ភាគហ៊ុនជាលើកដំបូងដោយក្រុមហ៊ុនឯកជនទៅកាន់សាធារណៈ។ នៅក្នុងដំណើរការ ក្រុមហ៊ុនបោះផ្សាយទទួលជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ដែលជួយក្រុមហ៊ុនកំណត់ពីប្រភេទមូលបត្រដែលត្រូវបោះផ្សាយលក់ ថ្លៃសម្រាប់ដំណើរការលក់ល្អបំផុត និងពេលវេលាដែលត្រូវឡើងទីផ្សារ។

IPO គឺជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈដែលសំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។ (ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ)។

**ហេតុអ្វីបានជាក្រុមហ៊ុនធ្វើ IPO?**

**រូបភាពទី៦៖** ការបោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ




ប្រភព៖ ឯកសារការស្វែងយល់ពីទីផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនធ្វើ **IPO** ដើម្បី៖

- ស្វែងរកមូលធនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន
- ក្រុមហ៊ុនអាចប្រកបរបរអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព
- ជំរុញឱ្យសាធារណជនស្គាល់ពីក្រុមហ៊ុន
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ និងការបោះផ្សាយលក់សញ្ញាបណ្ណ

- រក្សាបុគ្គលិកខ្លួន និងទាក់ទាញអ្នកមានសមត្ថភាព
- ដឹងពីគន្លឹះចូលទៅកាន់ទីផ្សារ។

## ៣.២ តួអង្គសំខាន់ៗដែលចូលរួមក្នុងកិច្ចដំណើរការ IPO

### ៣.២.១ CSX

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាហៅកាត់ថា (ផ.ម.ក) ឬ CSX( Cambodia Securities Exchange) គឺជាសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំ និងដាក់អោយដំណើរការទីផ្សារមូលបត្រនៅកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រនៅកម្ពុជាបានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ[10]។

**ក.ប្រតិបត្តិករទីផ្សារមូលបត្រ**

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅទៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជាការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ(ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ)ដើម្បីធ្វើសកម្មភាពជួយដូរមូលបត្រ ឬដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវបន្សុំលើប្រតិបត្តិការបញ្ជាទិញឬលក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយបម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក ។

**ខ.ប្រតិបត្តិករប្រពន្ធជាត់ទាត់និងទូទាត់មូលបត្រ**

ប្រតិបត្តិករប្រពន្ធជាត់ទាត់និងទូទាត់មូលបត្រ សំដៅទៅដល់បុគ្គលដែលធ្វើប្រតិបត្តិការប្រពន្ធជាត់ទាត់និងទូទាត់មូលបត្រ និងមានកាតព្វកិច្ចមួយចំនួនដូចជា :

១.ធ្វើប្រតិបត្តិការរបស់ខ្លួនអោយដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២.ត្រួតពិនិត្យនិងគ្រប់គ្រងដោយប្រុងប្រយ័ត្នរាល់ហានិភ័យដែលកើតឡើងពីអាជីវកម្មឬប្រតិបត្តិការណាមួយ។

៣.បំពេញអោយអស់ពីសមត្ថភាពនូវកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ អនុក្រឹតប្រកាសស្តីពីការផ្តល់ការអនុញ្ញាតធ្វើជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិនានាដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈឬផលប្រយោជន៍វិនិយោគិន។

[10] គេហទំព័រផ្សារមូលបត្រកម្ពុជាhttp://www.csx.com.kh

៤.អនុវត្តន៏អោយបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទុទាត់មូលបត្រ និងបទប្បញ្ញត្តិធរមានដែលកំណត់ដោយ គ.ម.ក ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នមាន សមត្ថកិច្ចពាក់ព័ន្ធ។

៥.ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់នូវប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន ព្រមទាំងប្រាជកថាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាអោយបាននូវសុវត្ថិភាពនិងប្រសិទ្ធិភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។

៦.ត្រូវផ្តល់របាយការណ៍ដែលធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនកម្មធ្វើអាជីវកម្មស្របច្បាប់និងបទប្បញ្ញាត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងទទួលស្គាល់ដោយអគ្គនាយក គ.ម .ក ។

៧.ត្រូវមានកាតព្វកិច្ចផ្តល់របាយការាណ៏ផ្សេងៗទៀត តាមការកំណត់របស់ គណៈកម្មការមូលបត្រកម្ពុជា។

**គ.ប្រតិបត្តិការរក្សាទុកមូលបត្រ**

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀតដែលជាអតិថជនរបស់ខ្លួនថាផ្តល់សេវាដូចខាងក្រោមនេះទោះបីជាអតិថជនធ្វើសកម្ម ភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ :

ក. កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត ក្នុងនាមអតិថជន ឬបុគ្គលផ្សេងទៀតដែលអតិថជនតែងតាំង ។

ខ. ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀតទោះបីមានរូបភាពជាវិញ្ញាបនប័ត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមអតិថជន ឬបុគ្គលផ្សេងទៀតដែលអតិថជនតែងតាំង ។

គ. ផ្តល់សេវាកម្ម និងលក្ខណះងាយស្រួលផ្សេងទៀតដែលទាក់ទិននឹងការផ្តល់សេវាកម្មដូចដែលបានចែងក្នុងកថាខណ្ឌ (ក)និង(ខ)។

ស្របតាមច្បាប់ស្តីពីការបោះផ្សាយមូលបត្រ និងការជួញដូរមូលបត្រមហាជនក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រព្រមទាំងជាប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា សព្វថ្ងៃមានតែក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមួយប៉ុណ្ណោះ ។

### ៣.២.២ IPO team

### ក.ក្រុមហ៊ុមធានាទិញមូលបត្រ(Securities Underwriters)

ក្រុមហ៊ុមធានាទិញមូលបត្រសំដៅដល់ក្រុមហ៊ុនដែលមានសិទ្ធិនៅក្នុងការប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្ររបស់ផ្សារមូលបត្រកម្ពុជា ។ នៅក្នុងការធ្វើអាជីវកម្មក្រុមហ៊ុមធានាទិញមូលបត្រអាចផ្តល់សេវាកម្មមួយចំនួនដល់អ្នកវិនិយោគសាធារណៈដូចជា : ផ្តល់ប្រឹក្សាសំខាន់លើ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ (IPO), ដូចជាការដាក់តម្លៃមូលបត្រ ការកំណត់ទំហំទឹកប្រាក់ និងចំនួនមូលបត្រនៃសំណើបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវាលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម ។

ទិញមូលបត្រទាំងអស់ ឬមួយផ្នែក ពីក្រុមហ៊ានបោះផ្សាយលក់មូលបត្រ ក្នុងគោលដៅ ចែកចាយ ឬលក់បន្ត ។ ទិញមូលបត្រដែលលក់មិនអស់ ឬមួយផ្នែកពីក្រុមហ៊ានបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ ។ ចែកចាយ និងរៀបចំដំណើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ានបោះផ្សាយមូលបត្រឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

ដើរតួជាអន្តរការី និងផ្តល់ប្រឹក្សាក្នុងការទិញ ឬលក់មូលបត្រឲ្យអ្នកវិនិយោគិន ដោយទទួលបានកំរៃជើងសារ ។ ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណក្នុងការធ្វើអាជីវកម្មធានាទិញមូលបត្រមានចំនួន ០៧ក្រុមហ៊ុនគឺ:

ក្រុមហ៊ុមធានាទិញមូលបត្រ(Securities Underwriters)

ភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី Phnom Penh Securities Plc.

អូ អេស ខេ ឥណ្ឌូចៃណាស៊ីយ្យូរីធី លីមីធីត OSK Indochina Securities Limited

កាណា ស៊ីយ្យូរីធី អិលធីឌី Cana Securities Ltd.

កម្ពុ ស៊ីយ្យូរីធី ភីអិលស៊ី Campu Securities Plc.

យាន់តា ស៊ីយ្យូរីធី (ខេមបូឌា) ភីអិលស៊ី TONGTANG Securities(Cambodia)Plc.

អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី SBI Securities Plc.

ខេមបូឌា -វៀតណាម ស៊ីយ្យូរីធី ភីអិលស៊ី Cambodai –Vietnam Plc.

### ខ. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ សំដៅដល់ក្រុមហ៊ុន ការិយាល័យ រឺក្រុមមេធាវីនិង មេធាវីដែលចូលរួមក្នុងក្រុមការងារ IPO មានតួនាទី

- ត្រួតពិនិត្យ និងផ្តល់យោបល់ពីការបំពេញកាតព្វកិច្ចផ្នែកច្បាប់
- ធ្វើរបាយការណ៍ បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់

## បញ្ជីឈ្មោះក្រុមហ៊ុន ការិយាល័យ និងក្រុមមេធាវី និងមេធាវី ផ្តល់សេវាផ្នែកច្បាប់នៅក្នុងវិស័យមូលបត្រ

បញ្ជាក់៖ ការរៀបចំបញ្ជីឈ្មោះក្នុងតារាងខាងក្រោមនេះធ្វើតាមលំដាប់ដែលក្រុមហ៊ុនទទួលបានស្គាល់ពី គ.ម.ក មិនឆ្លុះបញ្ចាំងពីលំដាប់គុណភាពនោះឡើយ។

**តារាងទី១**៖បញ្ជីនាម ក្រុមហ៊ុនដែលផ្តល់សេវាផ្នែកច្បាប់នៅក្នុងវិស័យមូលបត្រ

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| 1. ក្រុមហ៊ុនមេធាវី អេច ប៊ី អេសHBS LAW FIRM<br>2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូប៖<br>- លោក លី តៃសេង<br>- លោក ហាក់ សៀកលី | អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៤ និងទី ៥ ផ្លូវលេខ ១២០ សង្កាត់ផ្សារថ្មី ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២២៤ ៣៣៧<br>ទូរសារ : ០២៣ ២២៤ ១៣៦<br>អ៊ីម៉ែល : info@hbs.com.kh<br>គេហទំព័រ : www.hbs.com.kh |
| 1. ការិយាល័យមេធាវី អ អេន ធី សុខ អេនហេងR&T SOK & HENG LAW OFFICE<br>2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូប៖<br>- លោក សុខ ខាវ៉ាន់<br>- លោក ហេង ឆាយ | អគារការិយាល័យវឌ្ឍនៈ ជាន់ទី ១៧ អគារលេខ ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ១២២០២ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៣ ១១២<br>ទូរសារ : ០២៣ ៩៦៣ ១១៦<br>អ៊ីម៉ែល : info.kh@rajahtann.com<br>គេហទំព័រ : http://kh.rajahtannasia.com |

| | |
|---|---|
| 1. **ការិយាល័យមេធាវី សុក ស៊ីផាន់ណា និង សហការីជាសមាជិក ZICOlaw** SokSiphana&associates, a member of ZICOlaw<br>2. **មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូបៈ**<br>- លោក សុក ស៊ីផាន់ណា<br>- លោកស្រី ខៀវ មាលី | អគារការិយាល័យ មេយប៉ែង ជាន់ទី៨ លេខ ៨៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៩ ៨៧៨<br>ទូរសារ : ០២៣ ៩៩៩ ៨៧៨<br>អ៊ីម៉ែល : soksiphana@soksiphana.com<br>: soksiphana@yahoo.com<br>គេហទំព័រ : www.soksiphana.com |
| 1. **ការិយាល័យមេធាវី សិទ្ធិស័ក្តិ**SITHISAK LAW OFFICE<br>2. **មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០៣ រូបៈ**<br>- លោក ម៉ុក ច័ន្ទសុធា<br>- លោក តាន់ ម៉េងស្រួយ<br>- លោកស្រី ប៉េង ម៉ាណែត | ផ្ទះលេខ ១៣A ផ្លូវលេខ ៣៣៤ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៦៣៧៣ ១៦៨<br>អ៊ីម៉ែល : contact@sithisak-lawoffice.com<br>គេហទំព័រ : www.sithisak-lawoffice.com |
| 1. **ក្រុមមេធាវី អាស៊ី កម្ពុជា** ASIA CAMBODIA LAW FIRM<br>2. **មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូបៈ**<br>- លោកស្រី សេង រួចហ៊ុន<br>- លោក យិន សារ៉ុម | វីឡាលេខ ៦៥ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៤ ១៣៥<br>: ០២៣ ៩៩៤ ១៣៧<br>ទូរសារ : ០២៣ ៩៩៤ ១៣៤<br>អ៊ីម៉ែល : info@aclf.com.kh<br>គេហទំព័រ : www.aclf.com.kh |
| 1. **ការិយាល័យមេធាវី ប៊ុន និង សហការី**BUN & ASSOCATES<br>2. **មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មាន** | ផ្ទះលេខ ២៩ ផ្លូវលេខ ២៩៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៩ ៥៦៧ |

| | |
|---|---|
| **ចំនួន ០២ រូប៖**<br>- លោក ប៊ុន យូឌី<br>- លោក ឈិត វិនា | ទូរសារ : ០២៣ ៩៩៩ ៥៦៦<br>អ៊ីម៉ែល : info@bun-associates.com<br>គេហទំព័រ : www.bun-associates.com |
| **1. ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី PYT & Associates LAW OFFICE**<br>**2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូប៖**<br>- លោក យុន ប៉ោទឹម<br>- កញ្ញា ទ្រី សំរស់ | អាគារភ្នំពេញ (Phnom Penh Tower) ជាន់ទី ៦ លេខ ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៤ ៤៣០<br>អ៊ីម៉ែល : potim@vdb-loi.com<br>គេហទំព័រ : www.vdb-loi.kh |
| **1. ការិយាល័យមេធាវី ស៊ិនត្រលCentral Law Office**<br>**2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូប៖**<br>- លោក ស៊ិន សុពុទ្ធិ<br>- លោកស្រី ឈឹម សំអុល | ផ្ទះលេខ ៦៤ ផ្លូវលេខ ២៩៤ សង្កាត់បឹងកេងកង ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០១៥ ៧៤ ៧៤ ០០<br>: ០១២ ៤៨ ៧៩ ៧៣<br>អ៊ីម៉ែល : info@vinickassociates.com<br>គេហទំព័រ : www.vinickassociates.com |
| **1. ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាតាCSL & ASSOCIATES LAW OFFICE**<br>**2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០២ រូប៖**<br>- លោក ជា សុម៉ាឡា<br>- លោក ឆេង វណ្ណី | ផ្ទះលេខ ៤៤៥ ផ្លូវលេខ ២៣២ កែងនឹងផ្លូវលេខ ៩៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៤ ០២២<br>ទូរសារ : ០២៣ ៩៦៤ ០៣៣<br>អ៊ីម៉ែល : info@cslassociates.net |
| **1. ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន HML LAW GROUP & CONSULTANTS**<br>**2. មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក. មានចំនួន ០៣ រូប៖**<br>- កញ្ញា មៅ សំរុទ្ធារី | វីឡាលេខ ១៧៦ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២២០ ៩០០<br>ទូរសារ : ០២៣ ២២០ ១០០<br>អ៊ីម៉ែល : info@hml.com.kh |

| | |
|---|---|
| - កញ្ញា កង លាប<br>- កញ្ញា សេក សុវណ្ណា | គេហទំព័រ : www.hml.com.kh |

ប្រភព៖ គេហទំព័រគណៈកម្មាការមូលបត្រកម្ពុជា

### គ. ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដ៏ទៃទៀត ដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រ ត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់ពី គ ម ក ដើម្បីធ្វើសវនកម្ម នូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តអោយខ្ជាប់ខ្ជួននូវស្តង់ដាដែលបានកំណត់។

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវាក្នុងវិសយ័មូលបត្រដែលទទួលបានការទទួលស្គាល់ពី គ ម ក មានចំនួន ៦ ក្រុមហ៊ុន:

## បញ្ជីឈ្មោះក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ផ្តល់សេវានៅក្នុងវិស័យមូលបត្រ

<u>បញ្ជាក់</u>: ការរៀបចំបញ្ជីឈ្មោះក្នុងតារាងខាងក្រោមនេះ ធ្វើឡើងតាមលំដាប់ដែលក្រុមហ៊ុនទទួលបានការទទួលស្គាល់ពី គ.ម.ក. ពោលគឺមិនឆ្លុះបញ្ចាំងពីលំដាប់គុណភាពនោះឡើយ។

**<u>តារាងទី២</u>**៖ បញ្ជីនាមក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ផ្តល់សេវានៅក្នុងវិស័យមូលបត្រ

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| ១. ក្រុមហ៊ុន ប្រាយវែតធ័រ ហាវខូភើស៍ (ខេមបូឌា) PricewaterhouseCoopers (Cambodia) Ltd.<br>២. សវនករឯករាជ្យ មានចំនួន ០៣ រូប ៖<br>- លោក គុយ លីម<br>- លោកស្រី BENILDA FERNANDO<br>- លោក ឡាង ហ៊ី | អគារលេខ ៣៥ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២១៨ ០៨៦<br>ទូរសារ : ០២៣ ២១១ ៥៩៤<br>អ៊ីម៉ែល : contactus.cambodia@kh.pwc.com<br>គេហទំព័រ : www.pwc.com/cambodia |
| ១. ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា KPMG CAMBODIA LTD | អគារលេខ ១៩៤ ផ្លូវ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ |

| | |
|---|---|
| ២. សវនករឯករាជ្យ មានចំនួន ០៥ រូប ៖<br>- លោក ង៉ែ ហ៊ុយ<br>- កញ្ញា តាំង យុគហ្វុង<br>- លោក សេង ចាន់ថន<br>- លោក សុង គន្ធុល<br>- លោកស្រី ហ្គេក ទាវ | ទូរស័ព្ទ : ០២៣ ២១៦ ៨៩៩<br>ទូរសារ : ០២៣ ២១៧ ២៧៩<br>អ៊ីម៉ែល : audit@kpmg.com.kh<br>គេហទំព័រ : www.kpmg.com |
| ១. ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត<br>BDO CAMBODIA LIMITED<br>២. សវនករឯករាជ្យ មានចំនួន ០៥ រូប៖<br>- លោក GAN AH TEE<br>- លោក TANG SENG CHOON<br>- លោក LAW KIAN HUAT<br>- លោក LIM SENG SIEW<br>- លោក LEE KEN WAI | សណ្ឋាគារកាំបូឌីយ៉ាណា លេខ៣១៣ បន្ទប់លេខ២៨ វិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៩៣ ២២៦<br>ទូរសារ : ០២៣ ៩៩៣ ២២៥<br>អ៊ីម៉ែល : info@bdo.com.kh<br>គេហទំព័រ : www.bdo.com.kh |
| ១. ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)<br>ERNST & YOUNG (CAMBODIA) LTD.<br>២. សវនករឯករាជ្យ មានចំនួន ០៧ រូប ៖<br>- លោកស្រី ឡូន ស៊ិនរតនា<br>- លោកស្រី Maria Cristina Calimbas<br>- លោក Cuong Dinh Tran<br>- កញ្ញា Mary Rose S.Romero<br>- លោក Nguyen Xuan Dai<br>- លោក Jan Charlo Tan Pereras<br>- លោក Aileen Jamoral Tuliao | អាគារ Emerald Building លេខ ៦៤ ជាន់ទី៥ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ ១៧៨ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២១៧ ៨១៩/៨២៩/៨២៥<br>ទូរសារ : ០២៣ ២១៧ ៨០៥<br>អ៊ីម៉ែល : eykoc@vn.ey.com<br>គេហទំព័រ : www.ey.com |
| ១. ក្រុមហ៊ុន អង្គរ ស៊ីធីហ្វាយ អឺខោនធីន ណេតវើក អិមស៊ី មីលលែនរូដ (ខេមបូឌា) | ផ្ទះលេខ ១១០ $E_0$មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានី |

| | |
|---|---|
| ANGKOR CERTIFIED ACCOUNTANT NETWORK MC MILLAN WOODS (CAMBODIA) Co., Ltd<br>២. សវនករឯករាជ្យ មានចំនួន ០៥ រូប ៖<br>- លោក យូយាង ថាវរិទ្ធ<br>- លោក Mea Fatt Leong<br>- លោក Liew Lee Leong<br>- លោក Yau Hun Ling<br>- លោក Chong Loong Choy | ភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៨៨៣ ១៧៤<br>ទូរសារ : ០២៣ ៨៨៥ ២៣៤<br>អ៊ីម៉ែល : youkheang@camnet.com.kh |
| ១. ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត Grant Thornton (Cambodia) Limited.<br>២. សវនករឯករាជ្យ មានចំនួន ០៥ រូប ៖<br>- លោក Jasani Nareudrakumar<br>- លោក Hooi Kok Mun<br>- លោក Almera Ronald Coronel<br>- លោក គាត ហេង<br>- TAN CHEE BENG | វិមានកាណាឌីយ៉ា លេខ ៣១៥ ជាន់ទី២០ មហាវិថីព្រះមុន្នីវង្ស កែងផ្លូវព្រះអង្គ ឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។<br>ទូរស័ព្ទ : +៨៥៥ ២៣ ៩៦៦ ៥២០<br>ទូរសារ : +៨៥៥ ២៣ ៩៦៦ ៥២៦<br>អ៊ីម៉ែល : Info@kh.gt.com<br>គេហទំព័រ : http://www.gt.com.kh/ |

ប្រភព៖គេហទំព័រគណៈកម្មាការមូលបត្រកម្ពុជា

**ឃ. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ**

ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដ៏ទៃទៀត ដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យ ដែលទទួលបានកាទទួលស្គាល់ដោយ គ ម ក ដើម្បីវាយតម្លៃទ្រព្យសកម្ម ដោយអនុវត្តអោយបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ ម ក មានចំនួន៥ ក្រុមហ៊ុន:

# បញ្ជីឈ្មោះក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យ ផ្តល់សេវានៅក្នុងវិស័យមូលបត្រ

**តារាងទី៣៖** បញ្ជីនាមក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យផ្តល់សេវានៅក្នុងវិស័យមូលបត្រ

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| ១. ក្រុមហ៊ុន វីត្រាស់ អីព្រេហ្សល VTRUST APPRAISAL Co., Ltd.<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូប ៖<br>- លោក ភិន សុធារ<br>- លោក ស៊ីម ហ៊ុយឈ័ង | អគារលេខ ១១៣ ផាកវ៉េ ជាន់ទី១ មហាវិថីម៉ៅសេងទុង សង្កាត់ទូលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២២០ ០៩៨<br>អ៊ីម៉ែល : vap@vtrustappraisal.com<br>គេហទំព័រ : www.vtrustappraisal.com |
| ១. ក្រុមហ៊ុន រៀល អ៊ីស្ទេត វី.អិម.ស៊ី (ខេមបូឌា) អិលធីឌី REAL ESTATE V.M.C (Cambodia) Ltd<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូប៖<br>- លោកស្រី សេង វ៉ាន់ថា<br>- លោក មាច សុខសូដែន | ផ្ទះលេខ ១៣៨, ផ្លូវលេខ ៥១ កែង ២៩៤ សង្កាត់ បឹងកេងកង ទី១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ២២ ៩៥ ៣០<br>ទូរស័ព្ទដៃ : ០៧០ ៦៨ ៨៨ ៣៨/០១២ ៥០ ០១ ៥១<br>អ៊ីម៉ែល : info@vmcrealestate.com<br>គេហទំព័រ : www.vmcrealestate.com |
| ១. ក្រុមហ៊ុន ស៊ីប៊ី រីឆាត អែលលីស (ខេមបូឌា) ខមភេនី លីមីធីត CB RICHARD ELLIS(CAMBODIA) COMPANY LIMITED<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០១ រូប៖<br>- លោក SIMON JAY GRIFFITHS | អគារលេខ ៨៩៥ ភ្នំពេញថៅវើជាន់ទី៩ មហាវិថីព្រះមុនីវង្ស កែងផ្លូវ ២៣២ សង្កាត់ បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៤ ០៩៩/០៩៨ ៩៧ ០០ ៩៧<br>ទូរស័ព្ទដៃ : ០៨៩ ៧៧៧ ៣០៨/០៧៧ ៩៩ ៦២ ៧២<br>អ៊ីម៉ែល : cambodia@cbre.com |

| | |
|---|---|
| | គេហទំព័រ : www.cbre.com.kh |
| ១.ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា) Knight Frank (Cambodia) Pte., Ltd<br>២. អ្នកវាយតម្លៃឯករាជ្យ មានចំនួន ០២ រូបះ<br>- លោក ROSS WHEBLE<br>- លោក AMAURY PAYEN | បន្ទប់លេខ ១៦ B ជាន់ទី១៦ អគារកាណាឌីយ៉ា ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : ០២៣ ៩៦៦ ៨៧៨<br>ទូរស័ព្ទដៃ : ០១៥ ៥៣២ ០៧៥<br>ទូរសារ : ០២៣ ៩៨៦ ៦៥៨<br>អ៊ីម៉ែល : ross.wheble@kh.knightfrank.com<br>គេហទំព័រ : www.knightfrank.com.kh |

ប្រភព៖ គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា

### ៣.២.៣ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ

**ក. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** (Cash Settlement Agent)

- ធ្វើកាគ្រប់គ្រងគណនីយទូទាត់សាច់ប្រាក់ពាក់ពន្ធនិងមូលបត្រ ដូចជាការផ្ទេរ រឺការបង្វែរសាច់ប្រាក់ រវាងភាគីជួញដូរ
- ធ្វើប្រតិបត្តិការពាក់ពន្ធ័និងមូលបត្រ ប្រកបដោយសុវត្ថិភាព
- បំពេញកាតព្វកិច្ចអោយដាច់ដោយឡែកពីមុខងារប្រត្តិការធនាគារ
- ភ្នាក់ងារទូទាត់សាច់ប្រាក់ដែលទទួលបានពីការទទួលស្គាល់ពី គ ម ក មានចំនួន ៣ ធនាគារៈ

**បញ្ជីឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

**<u>តារាងទី៤</u>**៖បញ្ជីឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

| នាមករណ៍ក្រុមហ៊ុន | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|
| ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | អាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៨ ៧៧៧<br>ទូរសារ : ០២៣ ៩៩៨ ៦៦៦ |

| | | |
|---|---|---|
| | | អ៊ីម៉ែល : acledabank@acledabank.com.kh<br>គេហទំព័រ : www.acledabank.com.kh |
| | ធនាគារ កាណាឌីយ៉ា ក.អ<br>Canadia Bank Plc. | អាគារលេខ ៣១៥ មហាវិថីព្រះមុនីវង្ស កែងផ្លូវព្រះ អង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៨៦៨ ២២២<br>ទូរសារ : ០២៣ ៤២៧ ០៦៤<br>អ៊ីម៉ែល : canadia@canadiabank.com.kh<br>គេហទំព័រ : www.canadiabank.com.kh |
| | ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី<br>Bank for Investment and Development of Cambodia Plc. | អាគារលេខ ២៣ វិថីក្រមួនសកែងផ្លូវ ៦៧ សង្កាត់ផ្សារ ថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ២១០ ០៤៤<br>ទូរសារ : ០២៣ ២២០ ៥១១<br>អ៊ីម៉ែល : info@bidc.com.kh<br>គេហទំព័រ : www.bidc.com.kh |

ប្រភព៖គេហទំព័រគណៈកម្មាការមូលបត្រកម្ពុជា

## ខ. ភ្នាក់ងារបញ្ជិការមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ

១. ភ្នាក់ងារបញ្ជិការមូលបត្រ(Securities registrar agent):

**រូបភាពទី៧**៖ ភ្នាក់ងារបញ្ជីការមូលបត្រ




ប្រភព៖ ឯកសារស្វែងយល់ពីទីផ្សារមូលបត្រ

២. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ(Transfer agent):

**រូបភាពទី៨**៖ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ




ប្រភព៖ឯកសារស្វែងយល់ពីទីផ្សារមូលបត្រ

- រក្សារ និងគ្រប់គ្រងបញ្ជីកម្មសិទ្ធការមូលបត្រ អោយមានសង្គតិភាព
- រដ្ឋបាលកិច្ចពាក់ពន្ធ័និងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ ស្ថិតិ
- រៀបចំការងារពាក់ពន្ធ័និងកម្មសិទ្ធិករមូលបត្រ ដូចជាការជូនដំណឹង អំពីការបែងចែកភាគលាភ ការបង់ប្រាក់
- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដែលទទួលបានការទទួលស្គាល់ពី គ ម ក មានចំនួន ២ ក្រុមហ៊ុន:

**បញ្ជីឈ្មោះភ្នាក់ងារបញ្ជិកាមូលបត្រ, ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់**

**តារាងទី៥**៖បញ្ជីនាមភ្នាក់ងារបញ្ជិការមូលបត្រ,ភ្នាក់ងារចុះបញ្ជី ផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

| នាមករណ៍ក្រុមហ៊ុន | | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|---|
| | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | អាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៨ ៧៧៧<br>ទូរសារ : ០២៣ ៩៩៨ ៦៦៦<br>អ៊ីម៉ែល : acledabank@acledabank.com.kh<br>គេហទំព័រ : www.acledabank.com.kh |
| | ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរិធី សឺវីស ភីអិលស៊ី<br>Tricor Securities Services PLC. | អាគារលេខ អាអា០៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៨៧ ១០០<br>ទូរសារ : ០២៣ ៩៨៧ ៣៨៨<br>អ៊ីម៉ែល : info@tricorcambodia.com<br>គេហទំព័រ : www.tricorcambodia.com |

៣ .ភ្នាក់ងារទូទាត់មូលបត្រ (paying Agent):

**<u>រូបភាពទី៩</u>៖** ភ្នាក់ងារទូទាត់




ប្រភព៖ ឯកសារស្វែងយល់ពីទីផ្សារមូលបត្រ

- គណនាភាគលាភ ការប្រាក់ ប្រាក់ដើម
- ធ្វើការទូទាត់ជូនកម្មសិទ្ធិករ រឺភាគីពាក់ពន្ធ័ក្នុងនាមក្រុមហ៊ុនបោះផ្សាយ។
- បញ្ជូនពតមានចាំបាច់ដែលពាក់ពន្ធនិង ការទូទាត់ រឺពតមានដ៏ទៃទៀតដល់កម្មសិទ្ធិករមូលបត្រនិងតៅក្រុមហ៊ុនបោះផ្សាយ និង គ ម ក តាមការចាំបាច់។

### ៣.២.៤ ក្រុមហ៊ុនបោះផ្សាយ

ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ សំដៅដល់ក្រុមហ៊ុនទាំងឡាយដែលចុះបញ្ជីជាមួយ គ.ម.ក ដើម្បីធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិដាក់លក់ជាសាធារណៈនៅ ផ.ម.ក ទៅដល់វិនិយោគិនសាធារណៈ ក្នុងគោលបំណងគៀងគរដើមទុនបន្ថែមយកទៅពង្រីកអាជីវកម្មរបស់ខ្លួននាពេលបច្ចុប្បន្ន និងពេលអនាគត ដែលជាថ្នូរជាមួយវិនិយោគិនសាធាណរៈទាំងនោះវិញនូវការបែងចែកភាគលាភ ឬប្រាក់ចំណេញពីការទិញលក់មូលបត្រ និងភាពជាភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រណាមួយ។ ជាទូទៅ ក្រុមហ៊ុនដែលអាចចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅលើ ផ.ម.ក បានត្រូវតែជាក្រុមហ៊ុនដែលមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងតម្លាភាព។ សព្វថ្ងៃនេះ មានក្រុមហ៊ុនឬស្ថាប័នធំៗចំនួន៤ដែលបានចុះបញ្ជីលក់ភាគហ៊ុនរបស់ខ្លួនជាសាធារណៈនៅ ផ.ម.ក។

**៣.២.៥ វិនិយោគិនសាធារណៈ**

វិនិយោគិនសាធារណៈ សំដៅដល់អ្នកទិញ ឬអ្នកលក់មូលបត្រដែលធ្វើការជួញដូរមូលបត្រនៅ ផ.ម.ក។ វិនិយោគិនទាំងនេះអាចជាវិនិយោគិនសញ្ជាតិខ្មែរ ឬបរទេស អាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ វិនិយោគិន ជាបុគ្គលដ៏សំខាន់ចំពោះដំណើរការ ផ.ម.ក ដោយសារតែសន្ទុះនៃការជួញដូររបស់វិនិយោគិននឹងជះឥទ្ធិពលទៅលើថ្លៃមូលបត្ររបស់ក្រុមហ៊ុននៅលើទីផ្សារ។ ហេតុដូច្នេះហើយ បានជាវិនិយោគិនសាធារណៈទាំងអស់ត្រូវមានការយល់ដឹង និងវិភាគឲ្យបានស៊ីជម្រៅថាតើគួរវិនិយោគទៅលើក្រុមហ៊ុនបោះផ្សាយមួយណា និងក្នុងបរិមាណប៉ុន្មាន តាមរយៈការស្វែងយល់លម្អិតលើឯកសារផ្តល់ពត៌មានរបស់ក្រុមហ៊ុន ពត៌មានទាក់ទងនៅក្នុងគេហទំព័រ ផ.ម.ក និងក្រុមហ៊ុនបោះផ្សាយនីមួយៗ ការប្រឹក្សាជាមួយក្រុមហ៊ុនមូលបត្រឬអ្នកជំនាញ បទវិភាគផ្សេងៗ និងពត៌មានប្រចាំថ្ងៃដែលទាក់ទងនឹងភាគហ៊ុនជាដើម។ សព្វថ្ងៃនេះ មានវិនិយោគិនពី គ.ម.ក ក្នុងការវិនិយោគលើមូលបត្រនៅផ្សារមូលបត្រកម្ពុជា។

**៣.៣. យន្តការនៃការធ្វើ IPO**

យន្តការនៃការធ្វើ IPO មាន១២ដំណាក់កាលដូចតទៅនេះ[11]៖

**ដំណាក់កាលទី ១៖** *ដាក់លិខិតសម្តែង ឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (IPO)*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈអាចដាក់លិខិតសំដែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គ.ម.ក ដែលលិខិតមានខ្លឹមសារ០៣ចំណុចដូចខាងក្រោម៖

១.គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង(Purpose of IPO)។

២.គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Exspected Timetable)។

៣.ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុករួមមាន ក្រុមហ៊ុនធានាទិញមូលបត្រក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

[11] គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងលេខ០០១ ថ្ងៃទី០៨ ខែកញ្ញាឆ្នាំ២០១១

**ដំណាក់កាលទី២៖** *ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាល ដ៏សំខាន់ព្រោះ ក្រុមហ៊ុនធានាទិញមូល បត្រត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការធ្វើ IPO។ ក្រុមហ៊ុនធានា ទិញ មូល បត្រ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញារបណ្ណ័ពី គ.ម.ក ។

**ដំណាកើកាលទី៣៖** *ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គល សំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀតដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

**ដំណាក់កាលទី ៤៖** *ការត្រួតពិនត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លើកដំបូងដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

**ដំណាក់កាលទី ៥៖** *ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបាន ការបញ្ជាក់ ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ*

- ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ

- ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ (Listing Eligibility Review) ពី គ.ម.ក។
- ក្រុមហ៊ុនបោះផ្សាយ ត្រូវបង់ថ្លៃសេវាចំនួន ៤,០០០,០០០ រៀល( ទីផ្សារគោល) ឬ ២,០០០,០០០ រៀល (ទីផ្សាកំណើន) ជូន គ.ម.ក។
- ផ.ម.ក ត្រូវជូនដំណឹងពីលទ្ធផលក្នុងរយៈពេល១ ខែគិតពីការដាក់ពាក្យស្នើសុំ។

**ដំណាក់កាលទី ៦៖** *ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការទទួលបាន ការអនុញ្ញាត្តជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក។*

ក្រោយពីទទួលបានការបញ្ជាក់លទ្ធភាពអាចចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទីញមូលបត្រ ត្រូវរៀបចំឯកសារ ដាក់ពាក្យស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈមក គ.ម.ក ។

គ.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈជាពិសេស ឯកសារផ្តល់ពតិមានមុននិង ផ្តល់ការអនុញ្ញាត្តជាគោលការណ៍លើសំណើរបោះផ្សាយ លក់មូលបត្រជាសាធារណៈជូនមកក្រុមហ៊ុនបោះផ្សាយ។

**ដំណាក់កាលទី ៧៖** *ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង(Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយដែលមានជំនួយពី គ.ម.ក ក្រុមហ៊ុនធានាទិញមូលបត្រតាមរយៈប៊ុកបៀល ឌីង ពោលគឺការស្ទៀបស្ទង់តម្លៃលក់មូលបត្រជាមួយវិនិយោគិនសក្តានុពល មុននិងឈានដល់ការ កំណត់ថ្លៃលក់មូលបត្រ។

**ដំណាក់កាលទី៨៖** *ការស្នើរសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃមូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំស្នើរសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក។

ផ.ម.ក ត្រូវបញ្ជាក់ថាថ្លៃមូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូនវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃអាចត្រូវបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**ដំណាក់កាលទី ៩៖** *ការស្នើសុំអនុញ្ញាត្តលើលក្ខណ្ឌនៃសំណើលក់(Term of Offer) និងការទទួលបាន ការអនុញ្ញាត្ត និងការចុះបញ្ជី ពី គ.ម.ក។*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំលក្ខណ្ឌនៃសំណើរលក់ដោយត្រូវធ្វើបច្ចុបន្នកម្មឯកសារ ផ្តល់ពត៌មាននិងត្រូវភ្ជាប់លក្ខណ្ឌ មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក រួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការ អនុញ្ញាត និងការចុះបញ្ជីលក់។

**ដំណាក់កាលទី១០៖** *ការធ្វើបរិវិសកម្មមូលបត្រ(subscription)*

ក្រោយពីទទួលបានការអនុញ្ញាតិលើលក្ខខណ្ឌនៃសំណើរលក់ និងចុះបញ្ជីឯកសារផ្តល់ពត៌មានពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ដំណាក់កាលទី ១១៖** *កាភាយការណ៍ពីលទ្ធភាពនៃការធ្វើបរិវិសកម្មមូលបត្រ។*

ក្រោយពីបានបញ្ចប់ការ ធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំ របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មនេះភ្លាមជូន គ.ម.ក។

**ដំណាក់កាលទី១២៖** *ការចុះ បញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។*

- ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវបំពេញបែបបទទៅ ផ.ម.ក ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការដោយអនុលោមទៅតាមបទប្បញ្ញត្តិជាធរមាន។
- ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញបែប បទនេះក្នុងរយៈពេល៧ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម។

## ៣.៤. លក្ខខណ្ឌតម្រូវនៃការធ្វើ IPO?

### ៣.៤.១ ទីផ្សារគោល ( Main Board )

ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជាដែលមាននាទីចំបងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសការងារ អោយមានភាពល្អប្រសើរ

ដល់អ្នកចូលរួមក្នុងទីផ្សារជាពិសេសក្រុមហ៊ុនក្នុងស្រុក ដែលត្រូវការមូលធនដើម្បីពង្រីកអាជីវកម្ម ព្រមជាមួយនឹងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។

ក្នុងនោះផងដែរទីផ្សារគោលជាទីផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់អោយដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដានិងទំហំធំ។ ទីផ្សារនេះនឹងអនុញ្ញាតិអោយក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយ មកចុះបញ្ជី និងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផ.ម.ក[12]។

**<u>តារាងទី៦</u>**៖ លក្ខខណ្ឌតម្រូវក្នុងទីផ្សារគោល

| | |
|---|---|
| **លក្ខខណ្ឌបរិមាណ** | |
| មូលធនភាគហ៊ុនិក | ≥ ៣០ពាន់លានរៀល (៧,៥លានដុល្លារ) |
| ប្រាក់ចំណេញសុទ្ធ | ≥ ២ពាន់លានរៀល (៥០០.០០០ដុល្លារ) នៃឆ្នាំសារពើពន្ធចុងក្រោយ និង<br>≥ ៣ពាន់លានរៀល (៧៥០.០០០ដុល្លារ) នៃប្រាក់ចំណេញសរុបសម្រាប់រយៈ ពេ២(ពីរ)ឆ្នាំចុងក្រោយ |
| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% | ≥ ២០០នាក់ និង<br>≥ ៧% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ២ឆ្នាំ |
| **លក្ខខណ្ឌគុណភាព** | |
| ការផ្លាស់ប្តូភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេ | មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគែក្នុងរយៈពេល១ឆ្នាំរហូតដល់កាលបរិច្ឆេទចុះបញ្ជីជាផ្លូវការ។ |

[12] គេហទំព័រផ្សារមូលបត្រកម្ពុជា http://www.csx.com.kh

| | |
|---|---|
| ការរក្សាទុកមូលបត្រ | មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើរនៅប្រតិបត្តិការរក្សាទុកមូលបត្រនៃផ្សារមូលបត្រកម្ពុជា។ |
| ឡុកអាប់ភាគហ៊ុន | ក្នុង១ឆ្នាំសម្រាប់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (អនុញ្ញាតិអោយលក់ភាគហ៊ុនក្នុងកម្រិតអតិបរមា ៥០% សម្រាប់រយៈពេល៦ខែចុងក្រោយ)<br>ក្នុង៦ខែ សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% និងភាគហ៊ុនិកយុទ្ធសាស្ត្រ។ |
| **អភិបាលកិច្ចសាជីវកម្ម** | |
| ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (PLC) | • សមាជិកក្រុមប្រឹក្សាភិបាលពី ៥ ទៅ ១៥ នាក់<br>• អភិបាលឯករាជ្យ≥១/៥នៃអភិបាលសរុប<br>• ប្រសិនបើអភិបាលឯករាជ្យជាជនបរទេស ≥៦ខែនៃបទពិសោធន៍ការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| សហគ្រាសសាធារណៈ | ក្នុងសមាជិកក្រុមប្រឹក្សា≤៧នាក់<br>ក្នុងអភិបាលឯករាជ្យ≥១នាក់<br>ក្នុងអភិបាលមិនប្រតិបត្តិ(តំណាងអោយភាគហ៊ុនិកឯកជន)≥១នាក់ |
| គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល | ▪ គណៈកម្មាធិការសវនកម្ម<br>▪ គណៈកម្មាធិការគ្រប់គ្រងហានិភ័យសម្រាប់ទ្រព្យសកម្ម≥២០០ពាន់លានរៀល (៥០លានដុល្លារ) |

| | |
|---|---|
| | ▪ គណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការដទៃទៀតប្រសិនបើចាំបាច់និងតាមការស្នើសុំរបស់ គ.ម.ក។ |

### ៣.៤.២ ទីផ្សារកំណើន ( Growth Board )

ផ្អែកតាមអង្កេតចន្លោះជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១៤ (CIES 2014) របស់ក្រសួងផែនការចំនួនសហគ្រាសអាជីវកម្មសរុបនៅប្រទេសកម្ពុជាគិតត្រឹមខែ មីនា ឆ្នាំ ២០១៤ មានប្រមាណ ៥១៣,៧៥៩ ដែលក្នុងនោះប្រហែល៩៧%ជាសហគ្រាសខ្នាតតូចមានបុគ្គលិកក្រោម១០នាក់ ហើយមួយភាគបីនៃសហគ្រាសទាំងអស់មានអាយុកាលតិចជាងបីឆ្នាំ។ ទីផ្សារថ្មីសំរាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀតសម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។ដោយពិនិត្យឃើញអំពីសក្តានុពលនៃកំណើនរបស់សហគ្រាសទាំងនេះ យើងបានអោយឈ្មោះទីផ្សារថ្មីថា **«ទីផ្សារកំណើន»** ។

**តារាងទី៧៖** លក្ខខណ្ឌតម្រូវក្នុងទីផ្សារកំណើន

| | |
|---|---|
| **លក្ខខណ្ឌបរិមាណ** | |
| មូលធនភាគហ៊ុនិក | ≥២ពាន់លានរៀល(៥០០.០០០ដុល្លារ) |
| ប្រាក់ចំណេញសុទ្ធ | • ត្រូវមានប្រាក់ចំណេញសុទ្ធនៃឆ្នាំសារពើពន្ធចុងក្រោយ<br>• ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន និងត្រូវមានអត្រាប្រាក់ចំណេញដុល≥១០% |
| ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត តិចជាង ១% | ≥ ១០០នាក់ និង ≥១០% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ១ឆ្នាំ |
| **លក្ខខណ្ឌគុណភាព** | |
| ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមាន | មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគ |

| | |
|---|---|
| សិទ្ធិបោះឆ្នោតច្រើនជាងគេ | ហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល១ឆ្នាំរហូតដល់កាលបរិច្ឆេទចុះបញ្ជីជាផ្លូវការ។ |
| ការរក្សាទុកមូលបត្រ | មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើរនៅប្រតិបត្តិការរក្សាទុកមូលបត្រនៃផ្សារមូលបត្រ កម្ពុជា |
| ឡុកអាប់ភាគហ៊ុន | • ១ឆ្នាំសម្រាប់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (អនុញ្ញាតិឱ្យលក់ភាគហ៊ុនក្នុងកម្រិតអតិបរមា៥០%សម្រាប់រយៈពេល ៦ខែចុងក្រោយ)<br>• ៦ខែ សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% និងភាគហ៊ុនយុទ្ធសាស្ត្រ |
| **អភិបាលកិច្ចសាជីវកម្ម** | |
| ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (PLC) | • សមាជិកក្រុមប្រឹក្សាភិបាលពី ៥ទៅ១៥នាក់<br>• អភិបាលឯករាជ្យ≥១/៥ នៃអភិបាលសរុប<br>• ប្រសិនបើអភិបាលឯករាជ្យជាជនបរទេស≥៦ខែនៃបទពិសោធន៍ការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| សហគ្រាសសាធារណៈ | សមាជិកក្រុមប្រឹក្សាភិបាល ≤៧នាក់<br>អភិបាលឯករាជ្យ ≥១នាក់<br>អភិបាលមិនប្រតិបត្តិ(តំណាងឱ្យភាគហ៊ុនិកឯកជន)≥១នាក់ |

| | |
|---|---|
| គណៈកម្មាការនៃក្រុមប្រឹក្សាភិបាល | • គណៈកម្មាធិការសវនកម្ម<br>• គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សម្រាប់ទ្រព្យសកម្ម ≥២០០ពាន់លានរៀល(៥០លានដុល្លារ)<br>• គណៈកម្មាធិការតែងតាំង ក្រុមប្រឹក្សាភិបាលអាចពិចារណាបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការដទៃទៀតប្រសិនបើចាំបាច់ និងតាមការស្នើសុំរបស់ គ.ម.ក។ |

## ៣.៥. លក្ខខណ្ឌចូលរួមក្នុង ការចុះបញ្ជី

ដើម្បីធានាឲ្យបានជំនឿទុកចិត្ត ភាពជឿជាក់របស់វិនិយោគិន និងការការពារនូវផលប៉ះពាល់ដល់ប្រព័ន្ធហិរញ្ញវត្ថុក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូលផង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការត្រួតពិនិត្យកំណត់លក្ខខណ្ឌយ៉ាងត្រឹមត្រូវច្បាស់លាស់ ទៅលើស្ថាប័នទាំងឡាយណាដែលមានបំណងចង់បោះផ្សាយមូលបត្ររបស់ខ្លួនលក់ជាសាធារណៈ ។ លក្ខខណ្ឌសំខាន់ៗដែលត្រូវពិចារណា ទៅលើក្រុមហ៊ុនបោះផ្សាយទាំងនោះមានដូចជា[13]៖

**គុណភាពនៃអភិបាលកិច្ច៖** ក្រុមហ៊ុនបោះផ្សាយត្រូវធានាអោយបានពីគុណភាពខ្ពស់នៃការគ្រប់គ្រងសាជីវកម្ម ដែលសំដៅទៅលើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចរបស់ក្រុមហ៊ុន ការពារសិទ្ធិរបស់ភាគហ៊ុនិក ភាគីពាក់ព័ន្ធក៏ដូចជាអ្នកវិនិយោគសាធារណៈលើ មូលបត្រនៃក្រុមហ៊ុនបោះផ្សាយជាដើម ។ ដើម្បីបង្ហាញពីប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពខ្ពស់ ក្នុងការគ្រប់គ្រងជៀសវាងនូវការកើតឡើងជម្លោះរវាងអ្នកគ្រប់គ្រងនិងភាគហ៊ុនិក ដែលជាហេតុបង្កអោយមានការខាតបង់ និងការរាំងស្ទះដល់ភាពរីកចំរើនរបស់ក្រុមហ៊ុន ហើយជះឥទ្ធិពលអវិជ្ជមានផ្តល់ផលប្រយោជន៍រួមនៃភាគីពាក់ព័ន្ធទាំងអស់។ គោលការណ៍អភិបាលកិច្ចនេះ ត្រូវបានគេទទួលស្គាល់ថា ជាផ្នែកមួយនៃការធានានៃជំនឿទុកចិត្តរបស់វិនិយោគិនសាធារណៈទៅលើទីផ្សារមូលបត្រកម្ពុជា។

[13] ប៊ុត ស្រីនិច(២០១៦) សារណាបញ្ចប់ការសិក្សាស្តីពី "ដំណើរការទីផ្សារមូលបត្រកម្ពុជា" ទំព័រទី២៧

**ប្រវត្តិហិរញ្ញវត្ថុ៖** មុននឹងសំរេចចិត្តវិនិយោគលើមូលបត្រ របស់ក្រុមហ៊ុនបោះផ្សាយណាមួយ អ្នកវិនិយោគទាំងអស់ អាចនឹងវិភាគពីសក្តានុពលរបស់ក្រុមហ៊ុននោះ តាមរយៈរបាយការណ៍ហិរញ្ញវត្ថុ ដូច្នេះក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញពីប្រវត្តិហិរញ្ញវត្ថុរបស់ខ្លួន ដែលគោរពទៅតាមស្តង់ដាដែលបានកំណត់។ ក្រុមហ៊ុនទាំងនេះ ត្រូវតែមានប្រវត្តិហិរញ្ញវត្ថុរឹងមាំ មានតម្លាភាព និងមានគោលដៅច្បាស់លាស់លើតម្រូវការដើមទុន បន្ថែមដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

**លក្ខខណ្ឌតម្រូវការទីផ្សារ៖** តម្រូវការទីផ្សារជាកត្តាចំបង ដែលបង្ហាញពីការបណ្តឹងឬបើកចំហរចំពោះក្រុមហ៊ុនបោះផ្សាយ។ មានន័យថាពេលដំណើរការដំបូងគេត្រូវការចាំបាច់បំផុតនោះគឺការចូលរួមបោះផ្សាយមូលបត្រពីសំណាក់ក្រុមហ៊ុនដែលមានដំណើរការអាជីវកម្មល្អៗ អោយបានច្រើនដើម្បីធានានូវភាពជោគជ័យ និងការរីកចម្រើនរបស់ទីផ្សារ ពីព្រោះបើគ្មានក្រុមហ៊ុនបោះផ្សាយ ក៏គ្មានមូលបត្រដាក់លក់ជាសាធារណៈអោយសាធារណៈជនដែរ ហើយទីផ្សារក៏មិនមានដំណើរការទៅមុខដែរ។ដូច្នេះហើយ បានជាលក្ខខណ្ឌនៃការចូលរួមរបស់ក្រុមហ៊ុនត្រូវបានបន្ធូរបន្ថយពេលមិនមានក្រុមហ៊ុនច្រើនមានបំណងចុះបញ្ជីជាមួយទីផ្សារ។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តិអនុក្រឹត្យលេខ ៧០ អនក្រ.ប.ក ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តពន្ធដាក្នុងវិស័យមូលបត្រ ដែលផ្តល់ការលើកទឹកចិត្តដល់ទាំងក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិន លើទីផ្សារមូលបត្រកម្ពុជា ដើម្បីអភិវឌ្ឍទីផ្សារមូលបត្រអោយមានដំណើរការឈានទៅមុខជាលំដាប់។

**តម្រូវការឯកសារផ្តល់ពត៌មាន៖** រាល់ក្រុមហ៊ុនបោះផ្សាយទាំងអស់ត្រូវរៀបចំឯកសារផ្តល់ពត៌មានជូន គ.ម.ក ទៅតាមទម្រង់បែបបទ់ដែលបានកំណត់ដោយគ.ម.ក យោងតាមគម្រោងប្រកាសផ្សាយលក់ក្នុងវិស័យមូលបត្រកម្ពុជា គ.ម.ក បានរៀបចំទម្រង់ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវអោយក្រុមហ៊ុនបោះផ្សាយផ្តល់ពត៌មានទាក់ទងនឹងប្រវត្តិក្រុមហ៊ុន ស្ថានភាពហិរញ្ញវត្ថុ ដំណើរការអាជីវកម្ម យុទ្ធសាស្ត្រធុរកិច្ច និងផែនការអនាគត កត្តាហានិភ័យ គោលការណ៍បែងចែកភាគលាភជាដើម ការផ្សព្វផ្សាយជាសាធារណៈមុនពេលសំណើរលក់មូលបត្រអាចដំណើរការទៅបាន។ ឯកសារផ្តល់ពត៌មាននេះពិតជាមានសារៈសំខាន់ណាស់ ដល់វិនិយោគិនសាធារណៈ ក្នុងការសំរេចចិត្ត វិនិយោគលើមូលបត្ររបស់ក្រុមហ៊ុនណាមួយ ព្រោះពួកគេត្រូវធ្វើការប្រៀបធៀបយ៉ាងល្អិតល្អន់ទៅលើទំហំទុនដែលពួកគេមាន គោលបំណងនៃការវិនិយោគផលចំណេញដែលបានមកពីការវិនិយោគ ហានីភ័យដែលអាចកើតមានជាដើម ដែលផ្អែកទៅលើពត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវ គ្មានការក្លែងបន្លំពីក្រុមហ៊ុនបោះ

ផ្សាយទាំងនោះ។ដូច្នេះ ការត្រួតពិនិត្យលើឯកសារផ្តល់ពត៌មាន ពិតជាមានសារៈសំខាន់ក្នុងការធានានូវដំណើរការរីកចម្រើនរបស់ ផ.ម.ក ។

**លក្ខខណ្ឌមូលធនរបស់ក្រុមហ៊ុនបោះផ្សាយ៖** នៅប្រការបួននៃប្រកាសលេខ ០០១ គ.ម.ក ប្រក ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ បានកំណត់យ៉ាងច្បាស់ថា៖

ក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវមានមូលធនភាគហ៊ុនិក សរុបយ៉ាងតិច ៥០០០,០០០,០០០ (ប្រាំពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ដែលមូលធនភាគហ៊ុនិកនោះ សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

ចំពោះក្រុមហ៊ុនទាំងឡាយ ដែលមានមូលធនភាគហ៊ុនិកតិចជាង ២០,០០០,០០០,០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ ក្រុមហ៊ុនត្រូវបោះផ្សាយមូលបត្រចំនួនយ៉ាងតិច២០ភាគរយនៃមូលធនភាគហ៊ុនិកសរុប។ តែបើមូលធនភាគហ៊ុនិកសរុបក្រុមហ៊ុនចាប់ពី ២០,០០០,០០០,០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ ក្រុមហ៊ុនត្រូវធ្វើការបោះផ្សាយលក់មូលបត្រយ៉ាងតិច ១៥% នៃមូលធនភាគហ៊ុនិកសរុប។

ក្រុមហ៊ុនបោះផ្សាយត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ៥,០០០,០០០,០០០ (ប្រាំពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ។ លើសពីនេះសំរាប់រយៈពេលបីឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ ក្រុមហ៊ុនត្រូវមានផលចំណេញសរុបចំនួន ១០០០,០០០,០០០ (មួយពាន់លាន) រៀល ផងដែរ។

លក្ខខណ្ឌលម្អិតផ្សេងទៀតត្រូវបានបកស្រាយក្នុងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

## ៣.៦ ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូងសាធារណៈ

សព្វថ្ងៃនេះដំណើរការទីផ្សារមូលបត្រនៅប្រទេសកម្ពុជាមានក្រុមហ៊ុនចំនួន៥ដែលបានមកចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។ ក្រុមហ៊ុនទាំងនេះសុទ្ធសឹងជាក្រុមហ៊ុនធំៗ មានដំណើរការអាជីវកម្មល្អ និងមានចក្ខុវិស័យវែងឆ្ងាយ ធ្វើអោយដំណើរការអាជីវកម្មរបស់ខ្លួនឈានទៅមុខជានិច្ច។

### ៣.៦.១ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

រដ្ឋាករទឹកស្វ័យតក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាគ្រឹះស្ថានសាធារណៈ ស្ថិតនៅក្រោមច្បាប់អំពីសហគ្រាសសាធារណៈ។ រ.ទ.ស.ភ គឺជាអ្នកផ្គត់ផ្គង់ទឹកផ្តាច់មុខ នៅក្នុងរាជធានី

ភ្នំពេញ ផ្តល់សេវាផលិត និងផ្គត់ផ្គង់ ចែកចាយទឹកស្អាតដល់ប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញទាំងមូល។

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សាជាអ្នកសម្របសម្រួលដើម្បីអោយប្រជាពលរដ្ឋនៅក្នុងទីប្រជុំជនខេត្ត ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

បេសកកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺ ធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ២៤ម៉ោងក្នុងមួយថ្ងៃ៧ថ្ងៃក្នុងសប្តាហ៍មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននិងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹកខេត្ត ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរសំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅអភិវឌ្ឍសហស្សវត្សរ៍ពិភពលោក[14]។

ទន្ទឹមនឹងនេះដែរ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុនដែលស្មើនឹង១៥%នៃចំនួនភាគហ៊ុនធម្មតាសរុប។

**<u>រូបភាពទី១០</u>៖** សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង (IPO) របស់ រ.ទ.ស.ភ

| របាយការណ៍ហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | (លានរៀល) ២០១៦ |
|---|---|---|---|---|
| ទ្រព្យសកម្ម | 1,098,976.72 | 1,166,051.07 | 1,245,432.13 | 1,297,729.60 |
| ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 835,552.69 | 874,742.67 | 936,711.94 | 1,036,409.54 |
| ទ្រព្យសកម្មរយៈពេល | 252,538.36 | 287,958.25 | 306,077.62 | 259,091.13 |

[14] រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ:,២០១២

| | | | | |
|---|---|---|---|---|
| ខ្លី | | | | |
| សន្និធិ | 35,083.36 | 40,501.86 | 53,718.24 | 48,394.40 |
| គណនីត្រូវទទួល | 29,771.08 | 30,624.91 | 34,315.10 | 34,994.55 |
| សាច់ប្រាក់ | 10,568.72 | 14,962.14 | 12,555.44 | 16,386.85 |
| មូលធនរបស់ភាគហ៊ុនិក | 695,181.63 | 736,168.63 | 783,968.18 | 819,971.80 |
| ដើមទុន | 541,227.28 | 541,227.28 | 541,227.28 | 541,227.28 |
| ចំណេញរក្សាទុក | 38,088.03 | 45,747.91 | 56,949.13 | 49,273.10 |
| បំណុល | 403,795.09 | 429,882.45 | 461,463.95 | 477,757.80 |
| បំណុលរយៈពេលខ្លី | 56,551.73 | 53,256.51 | 64,809.75 | 78,253.95 |
| គណនីត្រូវបង់ | 29,859.91 | 21,509.97 | 27,308.00 | 33,384.27 |
| របាយការណ៍ចំណេញខាត | | | | |
| ចំណូល | 151,580.21 | 156,542.85 | 191,348.25 | 198,179.87 |
| ចំណេញដុល | - | - | - | - |
| ចំណេញប្រតិបត្តិការ | 51,532.93 | 44,651.58 | 54,642.64 | 57,469.47 |
| ចំណេញសុទ្ធ | 38,088.03 | 45,747.91 | 56,949.13 | 49,273.10 |
| ចំណេញក្នុងមួយភាគហ៊ុន[៩](រៀល) | 437.93 | 526.00 | 654.79 | 566.53 |
| របាយការលំហូរសាច់ប្រាក់ | | | | |

| | | | | |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | 74,840.50 | 84,204.48 | 78,919.84 | 100,564.04 |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | (112,044.95) | (101,087.81) | (81,663.02) | (74,697.59) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | 33,797.13 | 21,276.75 | 336.47 | (22,035.03) |
| **លំហូរសាច់ប្រាក់សុទ្ធ** | (3,407.32) | 4,393.43 | (2,406.71) | 3,831.41 |
| ក្រុមហ៊ុនសវនកម្មសម្រាប់ឆ្នាំ២០១៦ | | | Grant Thornton (Cambodia) Limited. | |

| ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO | |
|---|---|
| ថ្លៃ IPO (រៀល) | 6,300 |
| តម្លៃចារឹក (រៀល) | 1,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | 86,973,162 |
| ចំនួនភាគហ៊ុនបោះផ្សាយ | 13,045,975 |
| កាលបរិច្ឆេទជួញដូរដំបូង | 18 មេសា 2012 |
| ថ្លៃបិទដំបូង (រៀល) | 9,300 |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | តុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី<br>បច្ចុប្បន្ន យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

ប្រភពៈ គេហទំព័រផ្សារមូលបត្រកម្ពុជា

### ៣.៦.២ ក្រុមហ៊ុនប្រេគ្គនធ្វីន អ៊ីនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី (ហ.ធ.អ)

ហ.ធ.អ បានបង្កើតឡើងក្រោមច្បាប់ និងបទបញ្ញត្តិនៃព្រះរាជណាចក្រកម្ពុជា នាថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ មានឈ្មោះថា ប្រេគ្គន ធ្វីន អ៊ីនធើណេសិនណាល (ខេមបូឌា) អិលធីឌី។ នៅថ្ងៃទីទី១៩ខែកុម្ភៈឆ្នាំ២០១៣ក្រុមហ៊ុន ប្រេគ្គន ធ្វីន អ៊ីនធើណេសិនណាល (ខេមបូឌា) អិលធីឌី ត្រូវបានប្តូរទម្រង់ទៅជាក្រុមហ៊ុន ប្រេគ្គន ធ្វីន អ៊ីនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ីវិញ។ ថ្ងៃទី ១៦ខែកក្កដា ឆ្នាំ ២០០៨ ក្រុមហ៊ុន ប្រេគ្គន ធ្វីន បានទិញក្រុមហ៊ុន QMP Industrial Co, Ltd ដែលជារោងចក្រផលិតសំលៀកបំពាក់ឈានមុខមួយ ហើយដែលបានដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ៩០។ ក្រុមហ៊ុននេះបានធ្វើអាជីវកម្មរោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសំលៀកបំពាក់សំរាប់នាំចេញ ដែលសុទ្ធសឹងជាផលិតផលសំលៀកបំពាក់លីឡាម៉ាកល្បីៗដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance(NB), Kohl's Nautica, North Face, Russell Athletic ជាដើម និងធ្វើការនាំចេញទៅបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប សហរដ្ឋអាមេរិក តំបន់អាស៊ី និងបណ្តាប្រទេសដទៃទៀត[15]។

បេសកកម្ម របស់ក្រុមហ៊ុនគឺដើម្បីពង្រីកបន្ថែមចំពោះការចង់បានរបស់អតិថិជនទាំងគុណភាពការដឹកជញ្ជូន និងតម្លៃតាមរយៈការបន្តនូវការអនុវត្តឲ្យកាន់តែប្រសើរ និងទំនាក់ទំនងរវាងអតិថិជន។

ទន្ទឹមនឹងនេះ ហ.ធ.អ បានចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០១៤ ដោយបានបោះផ្សាយលក់ភាគហ៊ុនធម្មតាចំនួន ៨,០០០,០០០ ភាគហ៊ុន ដែលស្មើនឹង ២០% នៃចំនួនភាគហ៊ុនទាំងអស់របស់ខ្លួន។

**__រូបភាពទី១១__**៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង (IPO) របស់ ហ.ធ.អ

| របាយការណ៍ហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | (លានរៀល) ២០១៦ |
|---|---|---|---|---|
| ទ្រព្យសកម្ម | 191,272.68 | 289,976.82 | 304,850.95 | 333,328.39 |

[15] ក្រុមហ៊ុន ប្រេគ្គន ធ្វីន, ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ,២០១៤

| | | | | |
|---|---|---|---|---|
| ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 24,943.05 | 37,139.97 | 46,973.35 | 59,956.14 |
| ទ្រព្យសកម្មរយៈពេលខ្លី | 165,786.93 | 252,095.72 | 257,837.71 | 273,332.53 |
| សន្និធិ | 29,368.69 | 34,226.47 | 36,405.75 | 35,329.17 |
| គណនីត្រូវទទួល | 134,705.06 | 194,287.46 | 216,326.16 | 232,790.75 |
| សាច់ប្រាក់ | 1,713.18 | 23,581.79 | 5,105.80 | 5,212.62 |
| មូលធនរបស់ភាគហ៊ុនិក | 164,328.94 | 260,333.14 | 256,034.75 | 274,195.58 |
| ដើមទុន | 31,960.00 | 40,750.00 | 40,500.00 | 40,370.00 |
| ចំណេញរក្សាទុក | 132,368.94 | 149,167.14 | 145,550.75 | 164,066.22 |
| បំណុល | 26,943.74 | 29,643.69 | 48,816.20 | 59,132.81 |
| បំណុលរយៈពេលខ្លី | 26,943.74 | 29,643.69 | 48,815.24 | 49,865.21 |
| គណនីត្រូវបង់ | 8,302.66 | 8,415.56 | 15,116.07 | 12,674.44 |
| របាយការណ៍ចំណេញខាត | | | | |
| ចំណូល | 262,892.25 | 230,691.32 | 229,939.07 | 331,407.31 |
| ចំណេញដុល | 60,702.71 | 47,257.85 | 26,229.12 | 41,410.45 |
| ចំណេញប្រតិបត្តិការ | 36,801.61 | 18,454.91 | 3,603.41 | 16,114.53 |
| ចំណេញសុទ្ធ | 29,145.94 | 14,147.51 | 4,321.00 | 21,162.65 |
| ចំណេញក្នុងមួយភាគហ៊ុន[(9)] (រៀល) | 910.81 | 389.08 | 108.02 | 529.07 |
| របាយការលំហូរសាច់ប្រាក់ | | | | |

| | | | | |
|---|---|---|---|---|
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | 4,096.64 | (40,499.66) | (18,592.11) | 16,747.92 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (1,493.28) | (14,307.54) | (15,939.22) | (26,313.51) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | (4,566.85) | 76,641.50 | 16,200.00 | 9,688.80 |
| លំហូរសាច់ប្រាក់សុទ្ធ | (1,963.49) | 21,834.31 | (18,331.32) | 123.21 |
| ក្រុមហ៊ុនសវនកម្មសម្រាប់ឆ្នាំ២០១៦ | | | បីឌីអូ (ខេមបូឌា) លីមីធីត | |

| ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO | |
|---|---|
| ថ្លៃ IPO (រៀល) | 9,640 |
| តម្លៃចារឹក (រៀល) | 1,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | 40,000,000 |
| ចំនួនភាគហ៊ុនបោះផ្សាយ | 8,000,000 |
| កាលបរិច្ឆេទជួញដូរដំបូង | 16 មិថុនា 2014 |
| ថ្លៃបិទដំបូង (រៀល) | 9,220 |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ភ្នំពេញស៊ីយូរីធី ភីអិលស៊ី |

ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា

### ៣.៦.៣ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ)

ក.ស.ភ គឺជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាកំពង់ផែកុងតឺន័រអន្តរជាតិធំជាងគេទីពីរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ស.ភ ត្រូវបានបង្កើតតាំងពីពីឆ្នាំ ១៩០៥ ហើយបានក្លាយជាសហគ្រាសសាធារណ:ដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ តាមរយ:អនុក្រឹត្យលេខ ៥១ អនក្រ.បក។ មុនការបោះផ្សាយលក់មូលបត្រ ក.ស.ភ ជាសហគ្រាស

ដែលមានភាគហ៊ុនទាំងអស់កាន់កាប់ដោយរាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតំណាង។ ក.ស.ភ មានតួនាទីសំខាន់ពីរ គឺទីមួយមានតួនាទីជាអាជ្ញាធរគ្រប់គ្រងផែ ហើយទីពីរមានតួនាទីជាប្រតិបត្តិករផែ នៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញដូចដែលមានទីតាំងកំណត់ដោយអនុក្រឹត្យ[16]។

ចក្ខុវិស័យរបស់ ក.ស.ភ គឺរក្សាភាពជាអ្នកដឹកនាំក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេមេគង្គ និងដើរតួជាបណ្តាញដឹកជញ្ជូនតាមផ្លូវទឹក ប្រកបដោយប្រសិទ្ធិភាព និងសមត្ថភាព ដើម្បីភ្ជាប់ទំនាក់ទំនងដៃគូពាណិជ្ជកម្មក្រៅប្រទេស។

បេសកកម្មរបស់ ក.ស.ភ គឺគ្រប់គ្រងអភិវឌ្ឍ និងធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និងបម្រើសេវាកម្មចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមាននិរន្តភាពនៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីកចម្រើនក្នុងសង្គមជាតិទាំងមូល។

នៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១៥ ក.ស.ភ បានចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក ដើម្បីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។ ចំពោះការបោះផ្សាយលក់មូលបត្រនេះ ក.ស.ភ បានបោះផ្សាយមូលបត្រកម្មសិទ្ធិចំនួន ៤,១៣៦,៨៧៣ ភាគហ៊ុនដែលស្មើរនឹង ២០%នៃចំនួនភាគហ៊ុនដែលបានចុះបញ្ជីទាំងអស់។

**រូបភាពទី១២**៖ សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង (IPO) របស់ ក.ស.ភ

| របាយការណ៍ហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | (លានរៀល) ២០១៦ |
|---|---|---|---|---|
| ទ្រព្យសកម្ម | 613,787.22 | 612,990.29 | 647,909.44 | 659,556.91 |
| ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 572,530.99 | 568,417.61 | 568,455.03 | 585,996.36 |
| ទ្រព្យសកម្មរយៈពេលខ្លី | 9,634.55 | 12,906.03 | 47,349.35 | 39,103.47 |
| សន្និធិ | - | - | - | - |

[16] កំពង់ផែស្វយ័តភ្នំពេញ,ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ,២០១៥

| | | | | |
|---|---|---|---|---|
| គណនីត្រូវទទួល | 9,124.45 | 5,553.19 | 11,827.51 | 11,847.71 |
| សាច់ប្រាក់ | 510.10 | 7,352.84 | 35,521.84 | 27,255.76 |
| មូលធនរបស់ភាគហ៊ុនិក | 471,056.15 | 482,408.26 | 513,408.07 | 521,149.68 |
| ដើមទុន | 104,237.53 | 108,129.05 | 447,885.45 | 457,813.94 |
| ចំណេញរក្សាទុក | 339,604.55 | 345,878.19 | 12,829.70 | 12,820.18 |
| បំណុល | 142,731.08 | 130,582.04 | 134,501.38 | 138,407.23 |
| បំណុលរយៈពេលខ្លី | 21,616.93 | 7,866.44 | 10,316.34 | 11,278.27 |
| គណនីត្រូវបង់ | 7,917.13 | 6,574.38 | 7,714.37 | 9,303.12 |
| របាយការណ៍ចំណេញខាត | | | | |
| ចំណូល | 45,918.93 | 53,674.13 | 61,458.19 | 66,065.61 |
| ចំណេញដុល | 27,498.22 | 32,228.07 | 39,580.53 | 43,289.19 |
| ចំណេញប្រតិបត្តិការ | 11,536.72 | 16,532.85 | 22,442.37 | 24,435.34 |
| ចំណេញសុទ្ធ | 2,937.97 | 8,464.07 | 12,943.51 | 16,566.19 |
| ចំណេញក្នុងមួយភាគហ៊ុន[៦] (រៀល) | 177.55 | 511.5 | 770.07 | 800.90 |
| របាយការលំហូរសាច់ប្រាក់ | | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | 11,588.18 | 21,652.92 | 19,359.56 | 27,152.76 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (27,122.37) | (3,587.46) | (6,658.65) | (33,083.53) |
| លំហូរសាច់ប្រាក់ពី | 8,571.23 | 1,601.32 | 15,428.03 | (2,166.03) |

| | | | | |
|---|---|---|---|---|
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| **លំហូរសាច់ប្រាក់សុទ្ធ** | (6,962.96) | 19,666.77 | 28,128.94 | (8,096.81) |
| ក្រុមហ៊ុនសវនកម្ម សម្រាប់ឆ្នាំ២០១៦ | | | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

| ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO | |
|---|---|
| ថ្លៃ IPO (រៀល) | 5,120 |
| តម្លៃចារឹក (រៀល) | 4,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | 20,684,365 |
| ចំនួនភាគហ៊ុនបោះផ្សាយ | 4,136,873 |
| កាលបរិច្ឆេទជួញដូរដំបូង | 09 ធ្នូ 2015 |
| ថ្លៃបិទដំបូង (រៀល) | 5,140 |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ក្រុមហ៊ុនមូលបត្រយាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា

**៣.៦.៤ ក្រុមហ៊ុនភ្នំពេញ អេស អ៊ី ហ្សិត ភីអិលស៊ី** (PPSP)

ក្រុមហ៊ុន(PPSP) គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេស (PPSEZ) ឈានមុខគេមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបង្កើតឡើងនាថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៦។ បច្ចុប្បន្ន PPSEZ កំពុងប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ។ ធុរកិច្ចចម្បងរបស់ក្រុមហ៊ុននេះគឺធ្វើប្រតិបត្តិការ និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ដែលមានកម្មវត្ថុអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។ បន្ថែមពីនេះ ក្នុងនាមជាប្រតិបត្តិករក្រុមហ៊ុននេះបានចូលរួមផ្គត់ផ្គង់សេវាកម្មចាំបាច់ពាក់ព័ន្ធ និងបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមានការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាស

ម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំណល់ និងសេវាកម្មដទៃទៀត។ បច្ចុប្បន្ន ក្រុមហ៊ុនមានទីតាំងស្ថិតនៅលើផ្លូវជាតិលេខ ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ លើផ្ទៃដីទំហំធំជាងគេនៅកម្ពុជាដែលត្រូវនឹងប្រមាណ ៣៥៧.៣២ ហិចតា។ ក្រុមហ៊ុន PPSP មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួនពីរគឺ ក្រុមហ៊ុនសហ័ស ភីភីអេសអ៊ីហ្សិត និងក្រុមហ៊ុនប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត និងមានក្រុមហ៊ុនជាសម្ព័ន្ធភាពចំនួនពីរផងដែរគឺ ក្រុមហ៊ុនបុកសេង ភីភីអេសអ៊ីហ្សិត និងក្រុមហ៊ុន ខូសបេន ភីភីអេសអ៊ីហ្សិត ដែលសម្ព័ន្ធក្រុមហ៊ុនទាំងនេះមានការផ្តល់នូវសេវាសន្តិសុខ ផលិតនិងចែកចាយថាមពលអគ្គីសនី និងសេវាដែស្ទូតជូនដល់វិនិយោគិនតំបន់ និងអ្នកជួលដទៃទៀតក្នុង PPSEZ ។ ក្រុមហ៊ុននេះមានវិនិយោគុនច្រើនជាងគេនៅកម្ពុជា ដែលមានចំនួន ៧៧ វិនិយោគិនចម្រុះ ដែលភាគច្រនមកពីប្រទេសជប៉ុន ម៉ាឡេស៊ី តៃវ៉ាន់ ចិន សហរដ្ឋអាមេរិក និងកូរ៉េ ហើយធ្វើការវិនិយោគលើឧស្សាហកម្មផ្សេងៗគ្នា ដែលមានដូចជាគ្រឿងបន្លាស់យានយន្ត កាត់ដេរ អាហារ និងភេសជ្ជៈ ផលិតផលប្លាស្ទិច ផលិតផលអេឡិចត្រូនិច និងគ្រឿងអលង្ការជាដើម[17]។

ក្រុមហ៊ុន PPSP មានទស្សនៈវិស័យគឺធ្វើជាអ្នកអភិវឌ្ឍ និងប្រតិបត្តិករតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតគុណតម្លៃសម្រាប់ភាគហ៊ុនិក បុគ្គលដែលពាក់ព័ន្ធ ក៏ដូចជាសហគមន៍ផងដែរ។

បេសកកម្មរបស់ក្រុមហ៊ុន នេះ គឺក្លាយជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេនៅព្រះរាជាណាចក្រកម្ពុជា។ មានបំណងផ្តល់ឲ្យក្រុមហ៊ុនផលិតកម្ម នូវអត្ថប្រយោជន៍ផ្នែក ហិរញ្ញវត្ថុ ដើម្បីធានាដល់ការវិនិយោគរយៈពេលវែងស្របពេលដែលយើងមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក ដោយសារតែយើងមានហេដ្ឋារចនាសម្ព័ន្ធដែលទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិ ISO សេវាកម្មរដ្ឋបាលក្នុងតំបន់ និងទីតាំងល្អសម្រាប់ទូរគមនាគមន៍ក្នុងតំបន់។

PPSP ចុះបញ្ជីលក់មូលបត្រជាសាធារណៈជាផ្លូវការនៅ ផ.ម.ក នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ដែលបានបោះផ្សាយចំនួន ១១,៥៧៥,០០០ មូលបត្រដែលស្មើរនឹង ២០% នៃមូលបត្រកម្មសិទ្ធិសរុប។

[17] PPSEZ, ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈ, ២០១៦

**រូបភាពទី១៣៖** សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង (IPO) របស់ PPSP

| របាយការណ៍ហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | (លានរៀល) ២០១៦ |
|---|---|---|---|---|
| ទ្រព្យសកម្ម | 187,017.49 | 199,485.90 | 196,295.46 | 226,709.85 |
| ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | 39,891.93 | 57,361.01 | 57,146.11 | 59,645.81 |
| ទ្រព្យសកម្មរយៈពេលខ្លី | 112,034.17 | 94,176.71 | 92,294.89 | 117,955.26 |
| សន្និធិ | 72,023.53 | 44,615.47 | 53,205.07 | 69,270.45 |
| គណនីត្រូវទទួល | 30,755.53 | 48,776.58 | 34,368.73 | 38,948.58 |
| សាច់ប្រាក់ | 9,255.12 | 784.66 | 4,721.10 | 9,736.23 |
| មូលធនរបស់ភាគហ៊ុនិក | 69,065.07 | 94,397.98 | 110,506.32 | 146,309.87 |
| ដើមទុន | 3,995.00 | 4,075.00 | 93,757.50 | 116,820.69 |
| ចំណេញរក្សាទុក | 65,070.07 | 90,322.98 | 16,748.82 | 22,531.24 |
| បំណុល | 117,952.42 | 105,087.92 | 85,789.14 | 80,399.98 |
| បំណុលរយៈពេលខ្លី | 56,404.77 | 43,293.06 | 31,353.90 | 23,109.94 |
| គណនីត្រូវបង់ | 22,847.64 | 9,812.77 | 8,797.86 | 5,592.67 |
| របាយការណ៍ចំណេញខាត | | | | |
| ចំណូល | 66,780.66 | 95,159.06 | 66,330.40 | 38,190.45 |
| ចំណេញដុល | 32,888.71 | 50,979.79 | 41,685.94 | 26,569.50 |

| | | | | |
|---|---|---|---|---|
| ចំណេញប្រតិបត្តិការ | 20,873.06 | 34,752.06 | 24,929.17 | 9,522.08 |
| ចំណេញសុទ្ធ | 17,691.58 | 23,949.88 | 16,687.46 | 5,836.18 |
| ចំណេញក្នុងមួយភាគហ៊ុន[១] (រៀល) | 382.11 | 517.28 | 360.42 | 109.84 |
| របាយការលំហូរសាច់ប្រាក់ | | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | (1,394.01) | 8,580.58 | 24,771.27 | (13,663.67) |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | (16,801.28) | (18,484.19) | (6,016.10) | (11,916.78) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | 33,017.46 | 1,247.81 | (18,053.92) | 33,840.33 |
| លំហូរសាច់ប្រាក់សុទ្ធ | 14,822.16 | (8,655.79) | 701.25 | 8,259.88 |
| ក្រុមហ៊ុនសវនកម្ម សម្រាប់ឆ្នាំ២០១៦ | | | ប៊ីឌីអូ (ខេមបូឌា) លីមីធីត | |

| ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO | |
|---|---|
| ថ្លៃ IPO (រៀល) | 2,860 |
| តម្លៃចារឹក (រៀល) | 2,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | 57,875,000 |
| ចំនួនភាគហ៊ុនបោះផ្សាយ | 11,575,000 |
| កាលបរិច្ឆេទជួញដូរដំបូង | 30 ឧសភា 2016 |
| ថ្លៃបិទដំបូង (រៀល) | 2,890 |

| | |
|---|---|
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ១. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី<br>២. កម្ពុ ស៊ីយ្យូរីធី ភីអិលស៊ី<br>៣. កាណា ស៊ីយ្យូរីធី អិលធីឌី |

ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា

### ៣.៦.៥ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)

ក.ស.ស ជាក្រុមហ៊ុនរដ្ឋដែលបង្កើតឡើងនៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ និងជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ ហិចតា ដែលមានទីតាំងនៅក្នុងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ហើយដែលត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ។ តាមផ្លូវគោក ក.ស.ស ត្រូវបានតភ្ជាប់ដោយផ្លូវជាតិសំខាន់ៗពីរគឺផ្លូវជាតិលេខ៤ ដែលមានប្រវែង ២២៦ គីឡូម៉ែត្រ ដែលតភ្ជាប់ពីរាជធានីភ្នំពេញ និងផ្លូវជាតិលេខ៣កាត់តាមទីរួមខេត្តកំពត មានប្រវែង ២៤៤ គីឡូម៉ែត្រ។ ក.ស.ស ក៏ត្រូវបានតភ្ជាប់ដោយខ្សែរថភ្លើង ភាគខាងត្បូងពីរាជធានីភ្នំពេញ កាត់តាមខេត្តកំពត ដែលមានប្រវែងសរុប ២៦៤ គីឡូម៉ែត្រ។ តាមផ្លូវអាកាស ក.ស.ស ត្រូវបានតភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញដោយអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ[18]។

ក.ស.ស ធ្វើអាជីវកម្ម និងសេវាកម្មមូលដ្ឋានលើការងារដូចជា៖

- កណ្តាធារកិច្ច នាំនាវាចេញ ចូល និងផ្តល់ភស្តុភារដល់នាវា
- លើកដាក់ ផ្ទេរ ផ្ទុក ទំនិញ
- ស្តុកទំនិញ នៅឃ្លាំងនិងទីលាន
- ដឹកជញ្ជូនទំនិញ

ក្រៅពីអាជីវកម្មសេវាកម្មមូលដ្ឋានខាងលើ ក.ស.ស ក៏កំពុងផ្តល់សេវាកម្មខាងក្រោម៖

- សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសមានដូចជា ជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់និងដឹកជញ្ជូនទំនិញ
- សេវាកម្មសន្តិសុខក្នុងកំពង់ផែ និងក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែ។

ចក្ខុវិស័យរបស់ ក.ស.ស គឺ មានឆន្ទៈបំពេញតួនាទីជាកំពង់ផែមជ្ឈមណ្ឌលចែកចាយទំនិញនាំមុខគេសម្រាប់កម្ពុជា។

[18] កំពង់ផែស្វយ័តក្រុងព្រះសីហនុ,ឯកសារផ្តល់ពត៌មានសម្រាប់បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ,២០១៧

បេសកកម្មរបស់ ក.ស.ស គឺធានាបំពេញតម្រូវការរបស់អតិថិជនតាមរយៈការបង្កើតគុណភាពសេវាកម្ម ប្រតិបត្តិការឆាប់រហ័សជាងមុន និងតម្លៃសមស្រប។

នៅថ្ងៃទី០៨ ខែមិថុនាឆ្នាំ២០១៧នេះ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) បានរៀបចំ "ពិធីចុះបញ្ជីជាផ្លូវការរបស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ចំនួនភាគហ៊ុនបោះផ្សាយគឺ ២១,៤៥២,៩៩២។ឯកឧត្តម បណ្ឌិតបានគូសបញ្ជាក់ថាកំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) គឺជាក្រុមហ៊ុនទីប្រាំហើយដែលបានចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយគឺជាសហគ្រាសសាធារណៈទីបីបន្ទាប់ពីកំពង់ផែស្វយ័តភ្នំពេញ។

**<u>រូបភាពទី១៩</u>៖** សង្ខេបរបាយការណ៍ហិរញ្ញវត្ថុ និងពត៌មានពីការលក់ភាគហ៊ុនលើកដំបូង (IPO) របស់ ក.ស.ស

| របាយការណ៍ហិរញ្ញវត្ថុ | ២០១៣ | ២០១៤ | ២០១៥ | (លានរៀល) ២០១៦ |
|---|---|---|---|---|
| ទ្រព្យសកម្ម | - | 929,300.40 | 1,027,082.60 | 1,082,931.65 |
| ទ្រព្យសម្បត្តិ,រោងចក្រនិងបរិក្ខារ | - | 845,213.51 | 934,461.78 | 993,879.74 |
| ទ្រព្យសកម្មរយៈពេលខ្លី | - | 74,705.77 | 83,336.88 | 80,031.31 |
| សន្និធិ | - | 4,096.87 | 4,154.85 | 6,795.91 |
| គណនីត្រូវទទួល | - | 17,100.77 | 20,739.43 | 25,104.57 |
| សាច់ប្រាក់ | - | 36,577.80 | 45,229.80 | 34,651.60 |
| មូលធនរបស់ភាគហ៊ុនិក | - | 473,885.08 | 510,192.54 | 534,613.01 |
| ដើមទុន | - | 428,859.84 | 428,859.84 | 428,859.84 |
| ចំណេញរក្សាទុក | - | 35,257.68 | 69,087.30 | 90,783.31 |
| បំណុល | - | 455,415.33 | 516,890.06 | 548,318.64 |

| | | | | |
|---|---|---|---|---|
| បំណុលរយៈពេលខ្លី | - | 27,628.51 | 30,707.10 | 38,853.52 |
| គណនីត្រូវបង់ | - | 10,834.86 | 10,898.45 | 15,713.89 |
| របាយការណ៍ចំណេញខាត | | | | |
| ចំណូល | - | 168,966.63 | 198,839.02 | 208,981.25 |
| ចំណេញដុល | - | - | - | - |
| ចំណេញប្រតិបត្តិការ | - | 35,106.46 | 52,545.93 | 54,908.32 |
| ចំណេញសុទ្ធ | - | 35,301.80 | 38,307.46 | 26,720.47 |
| ចំណេញក្នុងមួយភាគហ៊ុន [១](រៀល) | - | 548.77 | 595.49 | 415.37 |
| របាយការលំហូរសាច់ប្រាក់ | | | | |
| លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ | - | 45,327.50 | 64,751.84 | 69,015.91 |
| លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ | - | (32,179.18) | (105,522.67) | (81,306.90) |
| លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន | - | (3,045.60) | 49,422.82 | 1,712.79 |
| លំហូរសាច់ប្រាក់សុទ្ធ | - | 10,102.72 | 8,652.00 | (10,578.20) |
| ក្រុមហ៊ុនសវនកម្មសម្រាប់ឆ្នាំ២០១៥ | | | Price Waterhouse (Cambodia) | |

| ព័ត៌មានអំពីការលក់ភាគហ៊ុនលើកដំបូង IPO | |
|---|---|
| ថ្លៃ IPO (រៀល) | 5,040 |
| តម្លៃចារឹក (រៀល) | 1,000 |
| ចំនួនភាគហ៊ុនចុះបញ្ជី | 85,771,967 |
| ចំនួនភាគហ៊ុនបោះផ្សាយ | 21,442,992 |
| កាលបរិច្ឆេទជួញដូរដំបូង | 08 មិថុនា 2017 |
| ថ្លៃបិទដំបូង(រៀល) | 5,100 |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី |

ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា

## ៣.៧ ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម

អនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០១ គ.ម.ក. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១០ ស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឲ្យការអនុវត្តប្រកបដោយរលូន និងមានប្រសិទ្ធិភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) សូមចេញនូវគោលការណ៍ណែនាំស្ដីពីការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើបរិវិសកម្ម (Subcription) មូលបត្រកម្មសិទ្ធិ ដូចខាងក្រោម[19]៖

### ៣.៧.១. ដំណាក់កាលប៊ុលបៀលឌីង

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុម

[19] គោលការណ៍ណែនាំ ស្ដីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លេខ ០០២/១២ គ.ម.ក/គ.ណ.ន ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២

ហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិន ឲ្យចូលរួម។

ដើម្បីជំរុញឲ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឲ្យប៊ុកបៀលឌីង មានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបម្រុងទុកសម្រាប់លក់ជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០ (សាមសិប) ភាគរយទៀត គឺត្រូវលៃបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង (Book-Building Form) ដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូល

ដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខ័ណ្ឌទី ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា។

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលជោគជ័យ បន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយ ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

### ៣.៧.២. ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្មអាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើលពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិស

កម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០ (ដប់) ភាគរយវិញបាន។

ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជីការមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata).

ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលុបដោយមានទាំង វិនិយោគិនជានីតិបុគ្គល ឬ/និង វិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលុប លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី ពីរភាគបី (២/៣) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនដ៏ច្រើនលើសលុបនោះ។

បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះវិញ។

ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែល

នៅសល់ ត្រូវធ្វើការបែងចែកទៅឲ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។

ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងទុកលម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា (Pro Rata)។

ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនទាបជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនទៅតាមការស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកទៅឲ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវលៃបម្រុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីង។

ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែង ក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់។

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

**៣.៨ រ៉ូដស្ងូ** ( RoadShow )

រ៉ូដស្ងូ គឺជាព្រឹត្តិការណ៍មួយដែលរៀបចំឡើងដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌ និងទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជាទៅលើសំណើរ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងក្នុងគោលបំណងដើម្បីកំណត់តំលៃថ្លៃលក់មូលបត្ររបស់ខ្លួន ដោយមានជំនួយជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយប្រើប្រាស់ព្រឹត្តិការណ៍នេះដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជា

មួយនឹងវិនិយោគិនសក្តានុពល និងធ្វើការផ្សព្វផ្សាយអំពីព័ត៌មានសំខាន់ៗរបស់ខ្លួនដែលរួមមាន ប្រវត្តិរបស់ក្រុមហ៊ុន រចនាសម្ព័ន្ធ ផែនការអាជីវកម្មទៅថ្ងៃអនាគត ភាពរីកចំរើនរបស់ក្រុមហ៊ុន សកម្មភាពអាជីវកម្ម និងព័ត៌មានហិរញ្ញវត្ថុសំខាន់ៗរបស់ក្រុមហ៊ុន[20]។

ក្រុមហ៊ុនបោះផ្សាយ ធ្វើដំណើរទៅកាន់គ្រប់ទីកន្លែង ក្នុងគោលបំណងជួបជាមួយវិនិយោគិនសក្តានុពល ដើម្បីបង្ហាញព័ត៌មានរបស់ខ្លួន។ រាល់ព័ត៌មាននិងទិន្នន័យដែលបបង្ហាញក្នុងព្រឹត្តិការណ៍រ៉ូដស្វ ត្រូវតែជាព័ត៌មានពិតដែលមិនបង្កអោយមានការយល់ច្រលំ ដល់បណ្តាវិនិយោគិនសក្តានុពល និងមានភាពត្រឹមត្រូវច្បាស់លាស់ទៅតាមការកំណត់របស់គណកម្មការមូលបត្រកម្ពុជា។ ក្នុងនោះដែរ

ក្រុមហ៊ុនបោះផ្សាយត្រូវតែបង្ហាញវឌ្ឍនភាព និងភាពរីកចំរើនរបស់ខ្លួនទៅកាន់វិនិយោគិនសក្តានុពល ធ្វើយ៉ាងណាអោយពួកគេមានទំនុកចិត្ត និងមានចំណាប់អារម្មណ៍ចង់វិនិយោគជាមួយខ្លួន។

ព្រឹត្តិការណ៍ រ៉ូដស្វនេះ ជាដំណាក់កាលសំខាន់មួយដែលចូលរួមអោយដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូងទទួលជោគជ័យ និងអនុញ្ញាតអោយក្រុមហ៊ុនបោះផ្សាយ ឈានទៅជំហានបន្ទាប់នៃការកំណត់ថ្លៃលក់មូលត្រតាមរយៈការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើវិភាគទានមូលតបត្រ (Subscription) ដែលនឹងមានការពន្យល់បន្ថែមទៅលើចំនុចនិមួយៗ នៅអត្ថបទក្រោយៗទៀត។

## ៣.៩ ការគ្រប់គ្រងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងសាធារណៈ

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជន ទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត[21]។

ការបោះផ្សាយលក់មូលបត្រមូលបត្រកម្មសិទ្ធបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

[20] ពុទ្ធិមូលបត្រ៖ ស្តីពី រ៉ូដស្វ (Roadshow) ចេញផ្សាយប្រចាំសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០១៦

[21] ប្រកាសស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

### ៣.៩.១ ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដាក់ពាក្យស្នើរសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ គ.ម.ក។

២.ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជារួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣. ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬ របាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២(ពីរ)ឆ្នាំ នៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ឆ្នាំនៃសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើរសុំដាក់ពាក្យសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៩៥ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើរសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤. ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥. ត្រូវមានឯកសារផ្តល់ពត៌មានដូចមានកំណត់ក្នុងប្រការទី៧ នៃប្រកាសរបស់ គ.ម.ក។ (សូមមើលប្រកាសបន្ថែម ប្រការទី៨-ប្រការទី ៣២[22])

### ៣.៩.២ ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បន្ទាប់ពីបានទទួលការអនុញ្ញាតិ និងចុះបញ្ជីឯកសារផ្តល់ពត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ពត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រាទី៧នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្ម ត្រូវបានបញ្ចប់ពេញលេញក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក គ.ម.ក។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវ តែរក្សាទុក

[22] ប្រកាសស្តីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក ប្រក ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៥

ប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជកម្មមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួននិងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ គ.ម.ក។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៥"ខ" នៃមាត្រា ៧ និងចំណុចទី២ នៃមាត្រា ១៨នៃអនុក្រឹត្យ និងប្រការ៣៨ និងប្រការ ៣៩ នៃប្រកាស។

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឲ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក គ.ម.ក ភ្លាម។

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម៖

- ១-២០ ភាគរយនៃសំណើរលក់សាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។
- ២-៨០ ភាគរយដែលនៅសល់ត្រូវបើកចំហរចំពោះវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ គ.ម.ក អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានា ភាពជោគជ័យនៃសំណើរបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៣.៩.៣ ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

ការផ្សព្វផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយពត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើរបោះផ្សាយ និងលក់មូលប

ត្រកម្មសិទ្ធិជាសាធារណៈត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតិជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ គ.ម.ក ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ[23]។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើរសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ពត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតិជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយក គ.ម.ក និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតិជាគោលការណ៍លើសំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ពត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយពត៌មាន រួមទាំងរ៉ូដស្ញូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវពតតមានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ គ.ម.ក និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ពត៌មានសម្រាប់ផ្តល់ឲ្យសាធារណៈជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយប្រតិបត្តិការទីផ្សារមូលបត្រ និងនៅ គ.ម.ក ក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ពត៌មានពីអគ្គនាយកនៃ គ.ម.ក ។

រយៈពេលយ៉ាងតិច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារពត៌មានដូចខាងក្រោម៖

១.ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២.ចំនួន និងឈ្មោះសាធារណៈជនអាចទទួលបានឯកសារផ្តល់ពត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៣.ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ពត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

[23] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនលេខ៥៤.អនុក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩

៤.កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥.សេចក្តីថ្លែង ដើម្បីឲ្យសារណៈជនដឹងថាសំណើរសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី គ.ម.ក រួចហើយ។

៦.សេចក្តីថ្លែងដើម្បីអោយសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ពត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឲ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧.កាលបរិច្ឆេទដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្តល់ពត៌មាន។

### ៣.៩.៤ តម្លៃសេវាក្នុងការចុះបញ្ជី

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ពត៌មាន នៅពេលដាក់ពាក្យស្នើសុំឲ្យ គ.ម.ក ដូចខាងក្រោម៖

១.ករណីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២,០០០,០០០ (ដប់ពីរលានរៀល) សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារ មូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះ បញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២. ករណីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៨,០០០,០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាឲ្យ គ.ម.ក នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ពត៌មានបន្ថែម និង/ឬឯកសារផ្តល់ពត៌មានជំនួស ដូចខាងក្រោម៖

១. ករណីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០,០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០,០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២. ករណីសិក្សាសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០,០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០,០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាឲ្យ គ.ម.ក នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ពត៌មានដែលអស់សុពលភាពដូចខាងក្រោម៖

១. ករណីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន៣,០០០,០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២. ករណីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២,០០០,០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក ក្រុមនាងខ្ញុំពិតជាទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀតដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងសារៈប្រយោជន៍របស់មូលបត្រចំពោះសេដ្ឋកិច្ចជាតិ យើងសង្កេតឃើញថាវិស័យមូលបត្រជាវិស័យថ្មីមួយសំរាប់ប្រទេសកម្ពុជា វាក៏ផ្តល់អត្ថប្រយោជន៍ជាច្រើនចំពោះវិនិយោគិន និងក្រុមហ៊ុនសហគ្រាសនានាកផងដែរ។ នៅក្នុងនេះផងដែរក៏បានរៀបរាប់ បង្ហាញពីទ្រឹស្តីផ្សេងៗទាក់ទងនឹងមូលបត្រ នៅជំពូកទី១។ ជំពូកទីពីរក៏បានរៀបរាប់ពណ៌នាពីស្ថានភាពទូទៅនៅ គណៈកម្មការមូលបត្រកម្ពុជា ជាពិសេសគឺ ចក្ខុវិស័យ និងបេសសកម្ម និងក្នុងជំពូកទីបី បង្ហាញអំពីកិច្ចដំណើរការការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងនៅកម្ពុជាហៅកាត់ថា IPO ផងដែរ។ ក្រៅពីនេះយើងឃើញថាក៏មានវិនិយោគិនមួយចំនួនកំពុងតែងាកមកយកចិត្តទុកដាក់ចំពោះវិស័យមូលបត្រមានការកើនឡើងជាលំដាប់ ព្រោះវាជាក៏ជាប្រភពមូលធនមួយដ៏មានសារៈសំខាន់ ដែលប្រទេសជិតខាង ឬប្រទេសអភិវឌ្ឍ មួយចំនួនធំបានដាក់ដំណើរការទីផ្សារមូលបត្រនេះយ៉ាងជោគជ័យរួចរាល់ហើយ ។

ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការនៃទីផ្សារនេះនៅតែមានបញ្ហាខ្លះៗ បង្កជាឧបសគ្គចំពោះការអភិវឌ្ឍ ដោយសារតែវិនិយោគិន នៅមិនទាន់ជ្រាបនិងយល់ច្បាស់ចំពោះវិស័យនេះម្យ៉ាងក៏មិនទាន់សម្របខ្លួនអោយយល់ដឹងពីគុណសម្បត្តិ និងគុណវិបត្តិ ជាពិសេសគឺថាប្រថុយប្រថាននានាផងដែរ ទើបបណ្តាលអោយវិស័យមូលបត្រក្នុងប្រទេសមិនទាន់មានសន្ទុះខ្លាំង។

ដូចនេះហើយទើបក្រុមយើងខ្ញុំបានសម្រេចសម្រួលចងក្រងឯកសារនេះឡើង សំរាប់ទុកជាចំណេះដឹងថ្មីមួយផ្នែកក្នុងវិស័យមូលបត្រ ក៏ដូចជាចំណេះដឹងសម្រាប់ចែកចាយជាពត៌មានជូនដល់ក្រុមនិស្សិត សិស្សានុសិស្ស ក៏ដូចជាបុគ្គលគ្រប់រូបដែលមានបំណងវិនិយោគលើមូលបត្រ និងងាកមកចាប់អារម្មណ៍អោយបានច្រើន អាចជាផ្នែកមួយជួយជំរុញកំនើនសន្ទុះវិស័យមូលបត្រនេះទៅថ្ងៃអនាគត។

## ២. អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកឃើញថា ទីផ្សារមូលបត្រកម្ពុជាមានចំណុចខ្វះខាតខ្លះៗ ដើម្បីចូលរួមចំនែកធ្វើអោយវិស័យនេះកាន់តែរីកចម្រើន និងដំណើរការប្រកបដោយសុវត្ថិភាព ក្រុមយើងខ្ញុំសូមចូលរួមបញ្ចេញមតិយោបល់មួយចំនួនដូចតទៅ៖

- រាជរដ្ឋាភិបាល គួរយកចិត្តទុកដាក់ និងផ្តោតសំខាន់ក្នុងការបណ្តុះបណ្តាលអប់រំចំពោះវិស័យនេះអោយបានច្រើន។
- គួរពង្រឹងច្បាប់ និងបទប្បញ្ញត្តិទាក់ទិននឹងការចុះបញ្ជីអោយបានតឹងរឹង ដើម្បីជាផ្តល់ជាទំនុកចិត្តចំពោះវិនិយោគិន។

# ឯកសារយោង

## ច្បាប់ អនុក្រឹត្យ និងសេចក្ដីប្រកាស


១. ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧

២. អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ២០០៩

៣. ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១០

៤. ប្រកាសស្ដីពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក ប្រក ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

៥. គោលការណ៍ណែនាំ ស្ដីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លេខ ០០២/១២ គ.ម.ក/គ.ណ.ន ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២


## សៀវភៅ


១. បៀន សាំង. ២០១១ *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*

២. ប៊ុត ស្រីនិច.២០១៦ *សារណាបញ្ចប់ការសិក្សាស្ដីពី "ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា"*

៣. បៀន សាំង ២០១២ *មូលបត្រកម្មសិទ្ធិ និងតម្លៃ*


## ឯកសារផ្សេងៗ


១. ពុទ្ធិមូលបត្រនានា គេហទំព័រគណៈកម្មាការមូលបត្រកម្ពុជា

២. ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ឯកសារផ្ដល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៣. កំពង់ផែស្វយ័តក្រុងព្រះសីហនុ ឯកសារផ្ដល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៤. កំពង់ផែស្វយ័តភ្នំពេញ ឯកសារផ្ដល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងសាធារណៈ

៥. ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ឯកសារផ្ដល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៦. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឯកសារផ្តល់ពត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

## គេហទំព័រ

១. http://www.acledasecurities.com.kh/as/khm/md_securitiesdictionary(ចូលទស្សនាថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៧)

២. គេហទំព័រផ្សារមូលបត្រកម្ពុជា:http://www.csx.com.kh/ (ចូលទស្សនាថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៧)

៣. គេហទំព័គណៈកម្មាការមូលបត្រកម្ពុជា:http//www.secc.gov.kh (ចូលទស្សនាថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៧)

៤. http://thachcenter.com/10/(ចូលទស្សនាថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៧)

# ឧបសម្ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តីវិស័យមូលបត្រ
# នៅកម្ពុជា

# ជំពូកទី២

# គណៈកម្មការមូលបត្រ

# កម្ពុជា

# ជំពូកទី៣

# ដំណើរការបោះផ្សាយមូលបត្រ(IPO)នៅកម្ពុជា

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# ឯកសារយោង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:..............................គ.ម.ក

**ទម្រង់ទី ០១**

(លេខប៊ុកបៀលឌីង :...............................)

## ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង
## នៃក្រុមហ៊ុន ..............................................

**ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនធានាទិញមូលបត្រ និងមូលបត្រកម្មសិទ្ធិ**

យើងខ្ញុំជាក្រុមហ៊ុនធានាទិញមូលបត្រ :................................................................................................................................។

ក្រុមហ៊ុនបោះផ្សាយ :....................................................... បានតែងតាំងក្រុមហ៊ុនមូលបត្រយើងខ្ញុំ....................................................................... (ឈ្មោះក្រុមហ៊ុនមូលបត្រ) ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ កាលពីថ្ងៃទី ........ ខែ ........ ឆ្នាំ ........... ។

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រយើងខ្ញុំ បានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មានជូន គ.ម.ក. ហើយទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. នៅថ្ងៃទី ...... ខែ ......... ឆ្នាំ ........។ ក្រុមហ៊ុនបោះផ្សាយបានកំណត់ថ្លៃលក់ចន្លោះពី...................... ដល់..................................ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

យើងខ្ញុំសូមបញ្ជាក់ថា វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ (Book-Building) ត្រូវជ្រើសរើសថ្លៃណាមួយក្នុងចំណោមចន្លោះថ្លៃដែលក្រុមហ៊ុនបានកំណត់។ វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ ត្រូវតម្កល់ប្រាក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលមានបំណងធ្វើបរិវិសកម្ម (សូមអានគោលការណ៍ណែនាំរបស់ គ.ម.ក. ស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដែលអាចទាញយកតាម http://www.secc.gov.kh/khmer/m24.php?pn=3 )។

វិនិយោគិនដែលមានបំណងចូលរួមក្នុងការស្ទាបស្ទង់ថ្លៃ សូមបំពេញនូវព័ត៌មាន ដូចខាងក្រោម÷

**ព័ត៌មានពាក់ព័ន្ធនឹងវិនិយោគិនចូលរួមធ្វើប៊ុកបៀលឌីង**

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :................................................................ ជាអក្សរឡាតាំង :..................................................................

ថ្ងៃខែឆ្នាំកំណើត :........................................... ភេទ : □ ប្រុស □ ស្រី
ទូរស័ព្ទលេខ :........................................... អ៊ីម៉ែល :...........................................។

លេខអត្តសញ្ញាណវិនិយោគិន[១] :...........................................

**ខ. វិនិយោគិនជានីតិបុគ្គល :**

□ នីតិបុគ្គលសញ្ជាតិខ្មែរ □ នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ
ឈ្មោះជាអក្សរខ្មែរ :........................................... ជាអក្សរឡាតាំង :...........................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ...........................................
ទូរស័ព្ទលេខ :........................................... អ៊ីម៉ែល :...........................................។

លេខអត្តសញ្ញាណវិនិយោគិន[២] :...........................................

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើប៊ុកបៀលនឹងតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

SPECIMEN

## ព័ត៌មានពាក់ព័ន្ធនឹងការស្ទាបស្ទង់ថ្លៃលក់មូលបត្រកម្មសិទ្ធិ

១. ថ្លៃមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :...........................................។
(វិនិយោគិន ត្រូវជ្រើសរើសយកថ្លៃមួយក្នុងចន្លោះថ្លៃ ដូចបានកំណត់ខាងលើ)
២. ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :...........................................
៣. ចំនួនទឹកប្រាក់សរុប (ថ្លៃមូលបត្រកម្មសិទ្ធិ x ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម) :...........................................។

ធ្វើនៅ.................. ថ្ងៃទី......... ខែ......... ឆ្នាំ.........

ហត្ថលេខា ឬ/និង ត្រា[៣]

ហត្ថលេខា- ត្រា និងឈ្មោះ

...........................................

**តំណាងក្រុមហ៊ុនមូលបត្រ** ឈ្មោះវិនិយោគិន

[១] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ករណីវិនិយោគិនជានីតិបុគ្គល

## គំរូវិក្កយបត្រ

## ប៊ុកបៀលឌីងមូលបត្រ

**វិក្កយបត្រប្រាក់តម្កល់នៃក្រុមហ៊ុនមូលបត្រ....................**

លេខប៊ុកបៀលឌីង:.........................

SPECIMEN

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើប៊ុកបៀលឌីងឈ្មោះ :...........................................................

លេខអត្តសញ្ញាណវិនិយោគិន :.....................................................

ចំនួនទឹកប្រាក់សរុបបានទទួល :...................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ............................ ធនាគារ :.........................................។

ហត្ថលេខា- ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...............................គ.ម.ក

**ឧបសម្ព័ន្ធទី ០២**

**លេខបរិវិសកម្ម :..............................**

**ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ**

**សម្រាប់វិនិយោគិនដែលបានចូលរួមធ្វើប៊ុកបៀលឌីង**

**ក្រុមហ៊ុនបោះផ្សាយ**...........................................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន .......................... ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ...................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ...................។ មូលបត្រកម្មសិទ្ធិសរុបដែលបែបម្រុងសម្រាប់បុគ្គលិកមានចំនួន .................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលបែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលបែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលបែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ ឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី ................................ ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

## ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

ឈ្មោះជាអក្សរខ្មែរ :............................................ ជាអក្សរឡាតាំង :............................................

លេខប៊ុកបៀលឌីង :............................................ លេខអត្តសញ្ញាណវិនិយោគិន :..............................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................. លេខគណនីជួញដូរ[១] :..................

[១] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១ ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611
E-mail : info@secc.gov.kh
Fax : 855-23-885-622

**ក. វិនិយោគិនដែលទទួលបានជោគជ័យ**

| ចំនួនមូលបត្រកម្មសិទ្ធិដែលបានបម្រុងឱ្យក្នុងប៊ុកបៀលឌីង | ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែងសរុបសម្រាប់ប៊ុកបៀលឌីង (១) |
|---|---|
| ........................................ | ........................................ |
| ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
| ........................................ | ........................................ |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | |
| ................................................................................ | |

**ខ. វិនិយោគិនដែលមិនទទួលបានជោគជ័យ**

| ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែងសរុបសម្រាប់ប៊ុកបៀលឌីង (១) | ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
|---|---|---|
| ........................................ | ........................................ | ........................................ |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | | |
| ................................................................................ | | |

SPECIMEN

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :........................................ ឬ ☐ ផ្សេងពីនេះ : ........................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញ

មូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____**

SPECIMEN

| | |
|---|---|
| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[២] |
| ...................................... | ...................................... |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

[២] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

## គំរូវិក្កយបត្រ
## បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នៃក្រុមហ៊ុនមូលបត្រ ..............................................**

SPECIMEN

លេខបរិវិសកម្ម :..............................

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើបរិវិសកម្មឈ្មោះ :.................................................................

លេខអត្តសញ្ញាណវិនិយោគិន :.......................................................

ចំនួនទឹកប្រាក់សរុបបានទទួល :...................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : .............................. ធនាគារ :............................................ ។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...............................គ.ម.ក

ទម្រង់ទី ០៣

លេខបរិវិសកម្ម :..............................

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ
## សម្រាប់វិនិយោគិនដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង
## ក្រុមហ៊ុនបោះផ្សាយ..............................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន .................... ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ........................ ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ...................... ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់បុគ្គលិកមានចំនួន ................ ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ .......................ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ ឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី ................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

**ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងការធ្វើបរិវិសកម្ម**

### ក. វិនិយោគិនជារូបវន្តបុគ្គល:

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :...................................... ជាអក្សរឡាតាំង :..........................................

ថ្ងៃខែឆ្នាំកំណើត :........................................... ភេទ : ☐ ប្រុស ☐ ស្រី

ទូរស័ព្ទលេខ :................................................ អ៊ីម៉ែល :...................................................។

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................. លេខគណនីជួញដូរ[១] :...................

[១] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១ ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

លេខអត្តសញ្ញាណវិនិយោគិន[២] :...............................................

**ខ. វិនិយោគិនជានីតិបុគ្គលៈ**

☐នីតិបុគ្គលសញ្ជាតិខ្មែរ ☐នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :........................................ ជាអក្សរឡាតាំង :........................................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ........................................

ទូរស័ព្ទលេខ :........................................ អ៊ីម៉ែល :........................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................... លេខគណនីជួញដូរ[៣] :..................

លេខអត្តសញ្ញាណវិនិយោគិន[៤]:...............................................

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើបរិវិសកម្មតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

SPECIMEN

## សំណើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

| ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលស្នើសុំធ្វើបរិវិសកម្ម | ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ចំនួនទឹកប្រាក់សរុបសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម |
|---|---|---|
| .............................. | .............................. | .............................. |

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលបានចូលរួមធ្វើបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :........................................ ឬ ☐ ផ្សេងពីនេះ :........................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៤] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

បដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញមូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្ដល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្ដល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____**

| | |
|---|---|
| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[៩] |
| ....................................... | ....................................... |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

SPECIMEN

[៩] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

## គំរូវិក្កយបត្រ
## បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនៃក្រុមហ៊ុន ....................................................**

លេខបរិវិសកម្ម :............................

កាលបរិច្ឆេទ : __/__/____

SPECIMEN

អ្នកធ្វើបរិវិសកម្មឈ្មោះ :.................................................................

លេខអត្តសញ្ញាណវិនិយោគិន :.......................................................

ចំនួនទឹកប្រាក់សរុបបានទទួល :......................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ............................ ធនាគារ :.........................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ